# សមាគម  កសិករ

## ១.  ហេតុអ្វីបង្កើតសមាគមកសិករ  តើវាមានសារៈសំខាន់យ៉ាងដូចម្តេច?

- ការផ្តល់ព័ត៌មានងាយស្រួល( មានក្រុម ឬងាយស្រួលបណ្តុះបណ្តាល)
- មានកំលាំង ឬ ឥទ្ធិពលក្នុងការចរចារតំលៃ ការពារសិទ្ធិ និងផលប្រយោជន៏
- ការជួយគ្នាទៅវិញទៅមក( គំនិត បទពិសោធន៏ ការសាមគ្គីភាព)
- ការធ្វើផែនការអភិវឌ្ឍន៏រួមគ្នា( កម្មវិធីអភិវឌ្ឍន៏ ផ្សេងៗ)
- ការប្រមូលផ្តុំផលិតផលលក់រួមគ្នា
- ភាពជាម្ចាស់ក្នុងការប្រើប្រាស់ធនធានធម្មជាតិក្នុងសហគមន៏( កើតក្នុងការទទួលខុសត្រូវ)
- ចំណេញពេលវេលា ថវិកា ឬកំលាំងពលកម្មក្នុងការសហការណ៏ធ្វើអ្វីមួយ ដូចជាលក់ផលិតផលជាដើម
- ភាពឯករាជ្យ និងម្ចាស់ការលើខ្លួនឯង ( អាស្រ័យខ្លួនឯង)

## ២.  តើដំណើរការក្នុងការបង្កើតសមាគមកសិករមានលក្ខណៈដូចម្តេច?

**១). ពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ:** ពិគ្រោះយោបល់ និងណែនាំគំរោងដល់អ្នកដែលពាក់ព័ន្ធ នៅតាមខេត្ត ស្រុក និងឃុំក្នុងតំបន់គោលដៅ ដើម្បីស្វែងយល់ពីស្ថានភាពកសិកម្ម និងសកម្មភាពផ្សេងៗ ក្នុងការអភិវឌ្ឍន៏នៅក្នុងសហគម និងដើម្បីជ្រើសរើសភូមិគោលដៅ ។

**២). ការចាប់ស្ពានរើស:** យើងជួបអ្នកភូមិនៅក្នុងភូមិគោលដៅដែលបានកំណត់ដោយមន្ត្រីនៅថ្នាក់ស្រុក ឬឃុំ ដើម្បីផ្ទៀងផ្ទាត់ពីព័ត៌មាននៅក្នុងភូមិឡើងវិញ ដើម្បីជ្រើសរើសភូមិអោយត្រូវតាមលក្ខណៈវិនិច្ឆ័យដែលយើងចង់បាន ។

**៣). សិក្សាពីតំរូវការ:** សិក្សាពីប្រពន្ធ័កសិកម្មនៅភូមិគោលដៅ ដោយស្វែងយល់ពីបទពិសោធន៏របស់កសិករ បញ្ហាដែលជួបប្រទះ ក៏ដូចជាដំណោះស្រាយ សក្តានុពល និងកត្តារារាំង ស្ថានភាពសង្គមសេដ្ឋកិច្ចនៅក្នុងភូមិ ដើម្បីមានមូលដ្ឋានសំរាប់បញ្ចូល គំនិតថ្មី ។ ព័ត៌មានដែលទទួលបាននេះជាព័ត៌មានមូលដ្ឋានគ្រឹះសំរាប់ការវាយតំលៃគំរោង ។

៤). **ពិគ្រោះយោបល់ជាមួយអ្នកភូមិដែលពាក់ព័ន្ធ:** យើងជួបប្រធានភូមិ តំណាងអ្នកភូមិគោលដៅ និងអ្នកពាក់ព័ន្ធផ្សេងៗ នៅក្នុងភូមិ ដើម្បីបង្ហាញនូវលទ្ធផលនៃការសិក្សា និងបង្ហាញគំរោង ឬគំនិតក្នុងការអភិវឌ្ឍន៍ នៅភូមិ និងដើម្បីជ្រើសរើសកសិករដែលចាប់អារម្មណ៍ទៅធ្វើទស្សនៈកិច្ចសិក្សា ។

៥). **ទស្សនៈកិច្ចសិក្សានៅក្រៅតំបន់:** រើសតំណាងកសិករចាប់អារម្មណ៍ ៤ ទៅ ៥ នាក់ ក្នុងមួយភូមិ ទៅធ្វើ ទស្សនកិច្ចសិក្សានៅតំបន់ដែលទទួលបានជោគជ័យ ដើម្បីបង្កើនភាពជឿជាក់ និងងាយស្រួលក្នុងការរៀនសូត្រ និងអនុវត្តរបស់កសិករ ។ កសិករដែលបានទៅធ្វើទស្សនៈកិច្ចសិក្សាត្រូវធ្វើការបង្ហាញដល់អ្នកភូមិដទៃទៀត ដើម្បីចែករំលែកនូវបទពិសោធន៍ និងជ្រើសរើសកសិករចាប់អារម្មណ៍សំរាប់ការបណ្តុះបណ្តាលខាងមុខ ។

៦). **ការបណ្តុះបណ្តាលដំបូង:** ជួបជុំកសិករដែលចាប់អារម្មណ៍ ដើម្បីណែនាំពីបច្ចេកទេសថ្មី និងជ្រើសរើសកសិករសហការសំរាប់រៀបចំការពិសោធន៍ ។ សំរាប់បណ្តុះបណ្តាលនេះ មានការបង្ហាញបទពិសោធន៍របស់កសិករបង្គោលដែលធ្វើបានជោគជ័យនៅតំបន់ផ្សេងៗ ។

៧). **ការគាំទ្រអោយមានការពិសោធន៍:** យើងមានការគាំទ្រកសិករអោយមានការពិសោធន៍ អោយមានការពិសោធន៍ជាក់លាក់នៅក្នុងភូមិ ។ យើងមានផ្តល់គ្រាប់ពូជ និងសម្ភារៈមួយចំនួនដើម្បីអោយកសិករដំណើរការពិសោធន៍ ។

៨). **ការជួបជាក្រុមជាទៀងទាត់** (Group dynamic): ការជួបជុំ តាមដាន និង ផ្តល់យោបល់បន្ថែមជាទៀងទាត់ដើម្បីរំលឹក មេរៀនផ្លាស់ប្តូរ បទពិសោធន៍ពីគ្នាទៅវិញទៅមក និងរៀនពីគំនិតថ្មីបន្ថែម ។ ការជួបជុំនេះដើម្បីបង្កើននូវវប្បធម៌ធ្វើការជាក្រុម និងជាឱកាសដើម្បីសំលឹងមើលអ្នកដែលលេចធ្លោ ។ យើងមានការជួបជាទៀងទាត់ជាមួយក្រុមកសិករយ៉ាងតិច ៨ដងសំរាប់មួយឆ្នាំ ។

៩). **ទស្សនៈកិច្ចសិក្សានៅក្នុងភូមិ ឬក្រៅភូមិ:** រៀបចំអោយអោយមានកសិករដទៃទៀតមកមើល និងរៀនសូត្រពីគ្នាទៅវិញទៅមកតាម រយៈធ្វើស្រែបង្ហាញ ទស្សនកិច្ចសិក្សា និងទិវាប្រមូលផល ។ល។

១០). **ការវាយតំលៃ និងឆ្លុះបញ្ចាំង:** ជាការជួបជុំឡើងវិញជាមួយអ្នកដែលពាក់ព័ន្ធដើម្បីវាយតំលៃទៅលើភាពសមស្របរបស់បច្ចេកទេស ក៏ដូចជាភាពរីកចំរើននៅក្នុងភូមិក្រោយពីសហការជាមួយគំរោងកន្លងមក ។

**១១). ការជ្រើសរើសកសិករបង្គោល:** ការប្រជុំដើម្បីជ្រើសរើស កសិករបង្គោលពី ៥ ទៅ ៧នាក់ ក្នុងមួយ ភូមិតាមរយៈសំរប សំរួលការបោះឆ្នោតដោយមានការចូលរួមពីកសិករសហការកន្លងមក ។

**១២). ការពង្រឹងកសិករបង្គោល**

- ជួបកសិករបង្គោលអន្តរភូមិជាទៀងទាត់រៀងរាល់ខែ
- បង្កលក្ខណៈអោយកសិករបង្គោលបង្រៀនដល់កសិករផ្សេងៗ ទៀត ដោយមានការសង្កេតពីគ្រូបណ្តុះបណ្តាល
- ពិសោធន៍សាកល្បងបច្ចេកទេសថ្មី ដើម្បីបង្ហាញ និងចែក រំលែកដល់អ្នកដទៃ
- ការចូលរួមប្រជុំ ឬសិក្ខាសាលាផ្សេងៗ
- ផ្តល់ឱកាសអោយកសិករបង្គោលដឹកនាំការប្រជុំនៅក្នុងភូមិ
- សំរបសំរួលអោយកសិករបង្គោលធ្វើផែនការ និងវិនិយោគលើកសិដ្ឋានរបស់ខ្លួន
- ទស្សនកិច្ចសិក្សាទៅតំបន់ផ្សេងៗ ដែលកសិករធ្វើបាន ជោគជ័យ
- ផ្តល់ឱកាសអោយកសិករបង្គោលប្រមូលព័ត៌មានសំខាន់ៗ និងភាពរីកចំរើននៅក្នុងភូមិ

បញ្ចូលគំនិតផ្តួចផ្តើមដំបូងក្នុងការរៀបចំជាសមាគម

**១៣). ការសំរបសំរួលក្នុងការបង្កើតសមាគមកសិករ**

- ស្ទាបស្ទង់ក្នុងការបង្កើតសមាគមនៅតាមភូមិគោលដៅ
- កសិករបង្គោលធ្វើចលនាអោយអ្នកគាំទ្រក្នុងការបង្កើតសមាគមក្នុងកំរិតភូមិ
- សំរបសំរួលក្នុងការជ្រើសរើសមេដឹកនាំសមាគមកសិករតាមរយៈការបោះ ឆ្នោត
- សំរបសំរួលបង្កើតលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសមាគមដោយមានការចូលរួម និងយល់ព្រម ពីសមាជិក ទាំងអស់

**លក្ខន្តិកៈរួមមាន**

ប្រវត្តិ ឈ្មោះ សញ្ញាសំគាល់ ទីតាំង ចក្ខុវិស័យ និងបេសកកម្ម សកម្មភាព រចនាសម្ព័ន្ធនៃការគ្រប់គ្រង និងដឹកនាំ អណត្តិ សមាជិកភាព លក្ខខណ្ឌចូលជាសមាជិកភាព ការទទួល ផលប្រយោជន៍របស់សមាជិក ការបញ្ឈប់ចូលជាសមាជិកភាព ការឧបត្ថម្ភ និងប្រភពថវិកា ការសហការជាមួយដៃគូ ការវិវត្តន៍របស់សមាគម និងអវសានរបស់សមាគម ។

**វិធីសាស្ត្រ  ឬដំណើរការបង្កើតលក្ខន្តិកៈ**

- បង្កើតគណកម្មការបណ្ដោះអាសន្នដើម្បី ពិភាក្សាធ្វើពង្រាង លក្ខន្តិកៈ
- គណកម្មការបណ្ដោះអាសន្នធ្វើសំវាទលក្ខន្តិកៈជាមួយសមាជិក ចាប់អារម្មណ៍
- បុគ្គលិកគំរោងជួយធ្វើការកែសំរួលលើលក្ខន្តិកៈ និងពិភាក្សាម្ដងទៀត
- គណកម្មការបណ្ដោះអាសន្ន និងសមាជិកដែលពាក់ពន្ធ័ធ្វើការ អនុមតិលើលក្ខន្តិកៈ
- បង្កើតក្រុមប្រឹក្សាភិបាលរបស់សមាគម( ករណីពិសេសសមស្រប)

**១៤). ការពង្រឹងមេដឹកនាំសមាគម**

- ការជួបជុំជាទៀងទាត់របស់ថ្នាក់ដឹកនាំសមាគមជាមួយអ្នកសម្រសម្រួលតាមរយៈផ្លូវការ និងក្រៅផ្លូវការ ក្នុង រយៈពេល ១ខែម្ដង
- ការពង្រឹងសមត្ថភាពរបស់ថ្នាក់ដឹកនាំសមាគមតាមរយៈ ការបណ្ដុះបណ្ដាល ចូលរួមសិក្ខាសាលា និង ទស្សនៈកិច្ចសិក្សាក្នុង និងក្រៅប្រទេស
- ផ្ដល់ឯកសារបច្ចេកទេសសំខាន់ៗ
- អ្នកដឹកនាំសមាគមមានការជួបជុំជាទៀងទាត់ជាមួយសមាជិករបស់ខ្លួន ដោយមានការសង្កេតពីបុគ្គលិក គំរោង
- បុគ្គលិកគំរោងចូលរួមក្នុងការវាយតំលៃ និងត្រួតពិនិត្យ សមាគម
- សមាគមរៀបឱ្យមានការពិសោធន៍នូវគំនិតថ្មីៗ

**១៥). គាំទ្រដល់សមាគមចំពោះកម្មវិធីអភិវឌ្ឍន៍នៅក្នុងសហគមន៍:** ជាការគាំទ្រដល់សមាគមជាថវិកា សម្ភារ: និងគំនិតផ្សេងៗ តាមរយៈកិច្ចព្រមព្រៀង ដើម្បីបង្កើតនូវកម្មវិធីផ្សេងៗ ដូចជាឥណទាន បង្កើតក្រុម អ្នក ផលិតនៅលើទីផ្សារ ការស្ដានូវហេដ្ឋារចនាសម្ពន្ធ័នៅក្នុងភូមិ និងការដាំដើមឈើឡើងវិញ ជាដើម ។

**១៦). ការភ្ជាប់ទំនាក់ទំនងសមាគមជាមួយអ្នកពាក់ពន្ធ័នៅក្នុងភូមិ:** រៀបចំអោយមានការជួបជុំគ្នារវាង សមាគម កសិករជាមួយអ្នកពាក់ពន្ធ័ផ្សេងៗ នៅក្នុងភូមិដូចជា ក្រុមប្រឹក្សាឃុំ គណៈកម្មាការអាចារ្យវត្ត គ្រូបង្រៀន និងអាជីវករ នៅក្នុងភូមិ ដើម្បីធ្វើការពិភាក្សាពីការអភិវឌ្ឍន៍នៅក្នុងភូមិ ។

**១៧). សំរបសំរួលភ្ជាប់ទំនាក់ទំនងពីសមាគមភូមិមួយទៅសមាគមភូមិមួយទៀត:** រៀបចំអោយមាន ការភ្ជាប់ទំនាក់ទំនង សមាគមកសិករភូមិមួយទៅភូមិមួយទៀត ដើម្បីបង្កើតជាសហពន្ធ័សមាគមកសិករ

នៅថ្នាក់ តំបន់ផ្សេងៗ ។ ការភ្ជាប់ទំនាក់ទំនងសមាគមនេះ ដើម្បីអោយសមាគមអាចជួយគ្នាទៅវិញទៅមក និង ជាកំលាំងមួយដ៏រឹងមាំ សំរាប់ការតស៊ូ និងការការពារសិទ្ធិ និងផលប្រយោជន៍របស់កសិករ ។

## ៣. រយៈពេលដំណើរការ

- ពីចំណុច ១ ដល់ ៨ រយៈពេល ១ឆ្នាំ ទៅ២ឆ្នាំ
- ការពង្រឹងកសិករបង្គោល រយៈពេល ១ ឆ្នាំ
- ចាប់ពីដំណើរការបង្កើតសមាគម រហូតដល់បង្កើតលក្ខន្តិកៈត្រូវការពេល ៦ខែ
- ការពង្រឹងសមាគមកសិកររយៈពេល ១ ឆ្នាំ

## ៤. លក្ខណៈវិនិច្ឆ័យដែលសមាគមមួយរឹងមាំ

- សមាជិករបស់សមាគមមានការជឿទុកចិត្តគ្នា សហការគ្នាល្អ និងគោរពច្បាប់ផ្ទៃក្នុង
- មានវចនាសម្ព័ន្ធ ទិសដៅ និងអត្តសញ្ញាណច្បាស់លាស់
- មានផែនការ និងយុទ្ធសាស្ត្រច្បាស់លាស់
- មានប្រព័ន្ធត្រួតពិនិត្យ និងវាយតំលៃត្រឹមត្រូវ
- មានអ្នកខាងក្រៅគាំទ្រ
- សមាគមអាចដំណើការសកម្មភាពរបស់ខ្លួនបានដោយស្មើរតែមិនចាំបាច់បានការជួយគាំទ្រពីខាងក្រៅ
- មានទុនបំរុងផ្ទាល់ខ្លួន
- អ្នកដឹកនាំមានសមត្ថភាព និងគ្រប់គ្រងបានល្អ

---

## ឧបសម្ព័ន្ធ៖ បច្ចេកទេសត្រូវផ្សព្វផ្សាយ

### ក. បច្ចេកទេសកសិកម្មទៅតាមប្រភេទដំណាំ និងសត្វ

- ប្រព័ន្ធប្រពលវប្បកម្មស្រូវតាមគោលការណ៍ធម្មជាតិ
- ឈើហូបផ្លែ
- ការដាំបន្លែតាមគោលការណ៍ធម្មជាតិ
- ការចិញ្ចឹមមាន់ (តាមគោលការណ៍ធម្មជាតិ និងពាក់កណ្ដាល ប្រពលវប្បកម្ម)
- ប្រព័ន្ធការចិញ្ចឹមទា ជាមួយស្រូវ
- ការចិញ្ចឹមជ្រូក
- ការចិញ្ចឹមត្រី និងការទាក់ទាញត្រីធម្មជាតិ
- ការបណ្ដុះផ្សិតចំបើង
- ឈើពហុប្រយោជន៍
- សួនបន្លែលក្ខណៈគ្រួសារ

### ខ. បច្ចេកទេសកសិកម្មទូទៅ

- បន្សុទ្ធពូជស្រូវ
- ការគ្រប់គ្រងជីជាតិដី (ជីស្រស់ និងការប្រើប្រាស់ជីធម្មជាតិ)
- កសិដ្ឋានពហុប្រយោជន៍
- ការគ្រប់គ្រងផលិតផលក្រោយពីប្រមូលផល
- ដំណាំចំណីសត្វ
- ការគ្រប់គ្រងកត្តាចង្រៃ និងវិធានការផ្សេងៗ ការពារដំណាំ
- ថ្នាំពុលការពារដំណាំ និងបញ្ហារបស់វា
- ចង្ក្រានកែលំអរ
- ប្រព័ន្ធអេកូឡូស៊ី
- វិទ្យាសាស្ត្ររបស់ដី និងវដ្តជីជាតិដី
- វដ្តនៃទឹក
- ការវិភាគប្រព័ន្ធក្សេត្របរិស្ថាន

By Cedac team 2003

- វិទ្យាសាស្ត្រកូជាតិ

**គ. ការគ្រប់គ្រង និងដឹកនាំ(សំរាប់ការពង្រឹងកសិករបង្គោល និងសមាគមកសិករ)**

- របៀបធ្វើការជាក្រុម
- របៀបប្រជុំ
- វិធីសាស្ត្រក្នុងការបង្រៀន
- ការរៀបចំផែនការអភិវឌ្ឍន៏កសិដ្ឋាន និងសហគម
- របៀបសរសេររបាយការណ៍
- របៀបប្រមូលទិន្នន័យ
- ការដោះស្រាយទំនាស់
- ការគ្រប់គ្រងឯកសារ និងថវិកា
- ការគណនាសាមញ្ញៗ
- របៀបគ្រប់គ្រងនិងដឹកនាំ

# ភាពជាអ្នកដឹកនាំ និងគ្រប់គ្រង

## ១. ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង :

| ភាពជាអ្នកដឹកនាំ | ការគ្រប់គ្រង |
|---|---|
| | - ការសំរបសំរួលអោយដល់ទិសដៅ និងតំរង់ទិស |
| - ដឹងពីមធ្យោបាយដើម្បីសំរេចទិសដៅ | - ចេះផ្សេរការងារ |
| - មានចំណេះដឹងច្រើន | - នាំគេធ្វើ |
| - ស្មោះត្រង់ | - ទទួលខុសត្រូវលើលទ្ធផល |
| - ភាពជាគំរូគេ | - ធ្វើឱ្យដំណើរការល្អ |

សរុបសេចក្តីមក ដើម្បីសំរេចបាននូវផែនការ ឬដើម្បីឱ្យការងារមានដំណើរការល្អ វាទាមទារឱ្យយើងមានទាំងពីរ គឺភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង ។

## ២. ទំលាប់ដែលធ្វើឱ្យមនុស្សមានប្រសិទ្ធភាពខ្ពស់

ដើម្បីឈានទៅរកការជួរទំលាប់ដែលនាំឱ្យមនុស្សកាន់តែមានប្រសិទ្ធភាពនោះ មានដូចខាងក្រោម :

- និយាយសាច់ការបានច្បាស់លាស់
- ធ្វើអ្វីតាមគំនិតរួម
- ធ្វើការងារផ្ទាល់ខ្លួនមានប្រសិទ្ធភាព
- ធ្វើការងារប្រាកដនិយម ( ព្យាយាមដាក់ចិត្ត )
- មានភាពទទួលខុសត្រូវ ខ្ពស់
- មានភាពក្លាហាន ( សួរ គិត សាកល្បង )
- មានចិត្តទូលាយ និងចេះចែករំលែកបទពិសោធន៍
- មានចិត្តអត់ធ្មត់ និងតស៊ូ

យើងអាចសរុបនូវទំលាប់របស់មនុស្សយើង ចេញពីកត្តា សំខាន់ៗ ៣រួមគ្នា គឺ :

១. ចំណេះដឹង

២. ជំនាញ

៣. សេចក្តីប្រាថ្នា/ការដាក់ចិត្ត




សរុបសេចក្តីមក ទំលាប់គឺត្រូវបានគេកំណត់ជាដំណាក់កាល ដូចខាងក្រោម :

១. ការផ្តើមគំនិត និងការទទួលខុសត្រូវ (Proactive)

២. ត្រូវកំណត់ក្នុងចិត្តថា តើចង់ចប់ត្រឹមណា ? ចង់បានអ្វី ?

៣. កំណត់នូវអាទិភាព ឬអ្វីដែលសំខាន់ជាងគេ (ទំលាប់ទាំង ៣ ខាងលើធ្វើឱ្យមនុស្សងាកពីការអាស្រ័យអ្នកដទៃ មកអាស្រ័យលើខ្លួនឯងវិញ)

៤. គិតឈ្នះៗ

៥. ហាត់ស្តាប់គេ និងព្យាយាមនិយាយឱ្យគេស្តាប់វិញ

៦. ការផ្តុំនូវចំណុចខ្លាំងចូលគ្នា

៧. គឺជាការរួមបញ្ចូលពីទី ១ ដល់ទី ៦ (១+២+៣+៤+៥+៦)

(ទំលាប់ពីទី ៤ ដល់ទី ៧ គឺធ្វើឱ្យមនុស្សងាកពីការអាស្រ័យលើខ្លួនឯង មកអាស្រ័យគ្នាទៅវិញទៅមក)។

ដូច្នេះ គោលបំណងនៃការហាត់ទំលាប់ខាងលើ គឺចង់ឱ្យមនុស្សមានការផ្លាស់ប្តូរពី :

ការអាស្រ័យលើអ្នកដទៃ → ការអាស្រ័យលើខ្លួនឯង → ការអាស្រ័យគ្នាទៅវិញទៅមក

## ៣. ការធ្វើខ្លួនឱ្យក្លាយជាមនុស្សមានប្រសិទ្ធភាពខ្ពស់

### ក) ការបណ្តុះគំនិត

- ហាត់សួរ ហាត់ឆ្លើយ
- ការប្រៀបធៀប ( ចំណុចរួម, ដូចគ្នា, ខុសគ្នា )
- ហាត់និយាយពីអ្វីមួយ
- ហាត់ឱ្យនិយមន័យ
- ការវិភាគ ( រាយ, រើស, រៀប, សំរាំង, សំរេច )
- ហាត់គ្រោងធ្វើអ្វីមួយ
- ហាត់រកចំណុចខ្លាំង ចំណុចខ្សោយ
- ចេះកំណត់អាទិភាព
- រៀបចំគំរោងធ្វើអ្វីមួយ
- កត់ត្រា និងសរសេរ
- ស្រមៃ បង្កើតរូបភាព
- ហាត់សំដែងកាយវិការ

### ខ) ការបណ្តុះសមត្ថភាព :

- ការដឹកនាំគ្រប់គ្រងសមាជិកគ្រួសារ
- ពិសោធន៍ សាកល្បង និងកត់ត្រា
- ការរៀបចំទុកដាក់ឯកសារ
- ការផ្ទេរការងារ
- ការស្រាវជ្រាវពត៌មានថ្មីៗ ( អាន, សំយោគ, សួរ, វិភាគ )
- គ្រប់គ្រងការចំណូលចំណាយ
- ការរៀបចំប្លង់កសិដ្ឋាន
- គ្រប់គ្រងការងារបច្ចេកទេស ( ការដាំ, ចិញ្ចឹម, ថែទាំ និងតាមដាន )

### គ) ការបណ្តុះចិត្ត

✪ ទឹកចិត្តដែលពិបាកសំគាល់ ឬពិបាកដឹង :

- ព្យាយាមការងារ អំណត់អត់ធន់
- ហ៊ានសំរេចចិត្ត
- ធ្វើអ្វីមួយបង្ហាញគេ
- ម៉ឺងម៉ាត់ក្នុងការងារ
- ហ៊ានទទួលខុសត្រូវ

✪ ចរិតខាងក្រៅដែលអាចសំគាល់បាន :

- ចេះចែករំលែកការងារ
- រួសរាយ រាក់ទាក់
- សុភាពរាបសារ
- ចេះចូលរួម និងជួយអ្នកដទៃ

✪ ដើម្បីសំរេចនូវការបណ្តុះចិត្តខាងលើទាមទារនូវ :

- ការបំផុសគំនិត
- មានចំណេះដឹងអ្វីមួយ
- ពន្យល់ណែនាំ
- មានការលើកទឹកចិត្ត ( សំភារៈ, ថវិកា, ពាក្យសំដី, បណ្ណសរសើរ )
- បង្កឱ្យមានការប្រកួតប្រជែង
- នាំទៅមើលកន្លែងដែលបានអនុវត្តហើយ
- មានការគាំទ្រពីក្រុមគ្រួសារ
- ជំរុញឱ្យមានការគាំទ្រខ្ពស់ពីអ្នកជិតខាង
- ហាត់គោរពពាក្យសន្យាខ្លួនឯង

លំហាត់ចំនួនពីរ ត្រូវបានលើកជា ឧទាហរណ៍ គឺការស្រមៃថា តើនៅពេលយើងស្លាប់ទៅ យើងចង់ឱ្យគេដទៃ (បងប្អូន កូនចៅ ញាតិមិត្តជិត ខាង) និយាយអ្វីខ្លះពីយើង និងតើយើងត្រូវធ្វើអ្វីខ្លះ ដើម្បីនាំកូន ទៅលេងអង្គរវត្តបាន។

**ឧទាហរណ៍ : យើងមានទិសដៅចង់ទៅលេងអង្គរវត្ត (ចំពោះកសិករ)**



# I. ការប្រជុំ

## ១.១. ដំណាក់កាល និងភាពទទួលបាននៃការប្រជុំ

- **ដំណាក់កាល**




- **ភាពទទួលបាន**

យើងរៀនតាមរយៈ:

- ការស្តាប់ ទទួលបាន ២០%
- ការស្តាប់ + មើលឃើញ ទទួលបាន ៥០%
- ការស្តាប់ + មើលឃើញ + ពិភាក្សា ទទួលបាន ៧០%
- ការស្តាប់ + មើលឃើញ + ពិភាក្សា + អនុវត្ត ទទួលបាន ៩០%

## ១.២. ប្រាំពីរចំណុចគួរពិចារណាដើម្បីរៀបចំការប្រជុំឱ្យមានប្រសិទ្ធិភាពខ្ពស់

① យល់ច្បាស់ អំពីហេតុអ្វីចាំបាច់មានការប្រជុំ ? (គោលបំណងច្បាស់លាស់)

② ដឹងថា អ្នកណាខ្លះនឹងត្រូវអញ្ជើញចូលរួម ? (អ្នកចូលរួម)

③ ជ្រើសរើស/រៀបចំទីកន្លែងប្រជុំឱ្យបានសមស្រប (ទីកន្លែង)

④ ជូនដំណឹងអំពីកម្មវិធីលំអិតឱ្យបានទាន់ពេលវេលា (របៀបវារៈ, ហេតុអ្វី, អ្នកណាចូលរួម, ពេលណា,

ទីណា និងរយៈពេលប៉ុន្មាន ?)

⑤ ដឹងថា ពេលណាត្រូវប្រជុំសំងាត់/ពេលណាប្រជុំចំហ

⑥ ចាប់ផ្ដើមទៀងពេល/ត្រៀមទប់ទល់ប្រការរំខានផ្សេងៗ

⑦ បង្ហាញផ្លូវ បែបបទ ច្រើនជាងនិយាយឱ្យស្ដាប់/អូសដៃ

## ១.៣. ដោយឈរលើគោលការណ៍"មូលរួម" យើងអាចបែងចែកការប្រជុំជា *ពីរប្រភេទធំៗ*

① ប្រជុំជូនដំណឹង/ផ្សព្វផ្សាយ : ជជែក/ពិភាក្សាតិចតួច
ឧទាហរណ៍ : ផ្សព្វផ្សាយសារាចររាជរដ្ឋាភិបាល សន្និសីទកាសែត

② ប្រជុំពិភាក្សា : ជជែក វែកញែក បកស្រាយ លំអិត សំរេច អនុវត្ត ប្រជុំចែករំលែក/ដោះដូរបទពិសោធន៍ ។

## ១.៤. សំនួរត្រិះរិះពិចារណាមួយចំនួនទាក់ទងនឹងការ"ប្រជុំ"

① អ្វីទៅ ដែលហៅថា "ការប្រជុំ" ?

② ហេតុអ្វី ចាំបាច់ជួបជុំ/ប្រជុំគ្នា ?

③ ការប្រជុំ មានប៉ុន្មានប្រភេទ ?

④ តើយើង គួរធ្វើអ្វីខ្លះ មុនពេលប្រជុំម្ដងៗ ?

⑤ តើយើង គួរធ្វើយ៉ាងណាខ្លះ ដើម្បីឱ្យការប្រជុំមានប្រសិទ្ធភាពខ្ពស់ ?

⑥ តួនាទី របស់អ្នកចូលរួម

⑦ តួនាទី របស់អ្នកដឹកនាំ/ប្រធានអង្គប្រជុំ

⑧ តើ យើងត្រូវធ្វើការសំរេចចិត្ត ដោយវិធីណា ?

⑨ តើ យើងគួរមានកំណត់ហេតុប្រជុំដែរឬទេ ? បើមាន ហេតុអ្វី ?

## ១.៥. តួនាទីអ្នកសំរបសំរួល/ប្រធានអង្គប្រជុំ

☑ ដឹកនាំអង្គប្រជុំ ដើម្បីសំរេចគោលដៅ

☑ ធ្វើការបរិយាយលំអិត និងថ្លឹងថ្លែងស្របតាមកម្មវិធីប្រជុំ

☑ ជួយជួចផ្ដើមគំនិត និងតំរង់ទិសដឹកនាំក្រុមពិភាក្សាឱ្យមានសន្ទុះខ្លាំងក្លា

☑ ជួយផ្សះផ្សាត់នូវគំនិតផ្សេងៗ មតិ/យោបល់

☑ បង្កបរិយាកាសចូលរួមល្អប្រសើរ

## ១.៦. អ្នកសំរបសំរួល មិនមែនជា :

✓ ចៅហ្វាយ/ថៅកែ ( កុំគ្របសង្កត់អ្នកដទៃ )

✓ អ្នកសំរេច និងធ្វើផែនការជំនួសអ្នកដទៃ

✓ អ្នកកំណត់នូវខ្លឹមសារ/លទ្ធផលលំអិត

✓ អ្នកបកស្រាយជំនួសមុខ អ្នកចូលរួម

✓ ជំនះយកតែមតិខ្លួនឯង

## ១.៧. កត្តាមួយចំនួន សំរាប់បង្កបរិយាកាសល្អឱ្យមានការចូលរួម

① ចូលរួមប្រជុំដោយអារម្មណ៍បើកចំហ

② ចាប់ផ្តើមប្រជុំដោយមានស្នាមញញឹម និងស្វាគមន៍កក់ក្តៅ

③ ទទួលស្គាល់អំពីភាពខុស/ប្លែកគ្នា (ចរិត, មតិយោបល់ ... ) របស់អ្នកចូលរួម

④ ទទួលស្គាល់អំពី សមត្ថភាពជំនាញ និងទេពកោសល្យរបស់មនុស្សម្នាក់

⑤ ថ្លែងកោតសរសើរ និងអរគុណក្នុងករណីចាំបាច់

⑥ ទទួលដោយរីករាយអំពីភាពប្រជែងរបស់អ្នកដទៃ

⑦ ត្រូវប្រាកដប្រជា និងស្មោះត្រង់

## ១.៨. តួនាទីអ្នកចូលរួម

✳ រួមចំណែក ចែករំលែក និងពិភាក្សាអំពីចំណេះដឹង និងបទពិសោធន៍ លើប្រធានបទកំណត់រួច

✳ ព្យាយាមស្វែងយល់ អំពីបញ្ហាលើកឡើង

✳ ស្តាប់អ្នកដទៃ

✳ ជួយជ្រោមជ្រែង ពេលណាក្រុមពិភាក្សាគាំងត្រង់ចំណុចណាមួយ

✳ ទទួលយកនូវគំនិតថ្មីៗ និងការតិះទៀនក្នុងន័យស្ថាបនា

✳ គោរពអ្នកចូលរួមផ្សេងទៀតក្នុងភាពស្មើគ្នា មិនគិតអំពីឋានៈ វណ្ណៈភាព និងពណ៌សម្បុរ

## ១.៩. ប្រាំមួយចំណុចគួរពិចារណា ដើម្បីក្លាយខ្លួនជាអ្នកបកស្រាយ/បង្ហាញល្អ

① ដឹងពីពេលវេលា ( ពេលណាត្រូវនិយាយអ្វី ? )

② បកស្រាយអំពីបញ្ហានោះ ដែលអ្នកចូលរួមចាប់អារម្មណ៍ និងយកចិត្តទុកដាក់

③ ប្រើប្រាស់ភាសាសាមញ្ញ ( ភាសាប្រចាំថ្ងៃ )

④ កុំនិយាយលើកខ្លួនឯង ( អួត )

⑤ បញ្ចេញកាយវិការសមស្រប

⑥ រក្សាទំនាក់ទំនងតាមក្រសែភ្នែក និងភ្នែក

## ១.១០. ប្រាំចំណុចគួរពិចារណា ដើម្បីឱ្យអ្នកចូលរួមយកចិត្តទុកដាក់ស្តាប់/តាមដាន

① សង្កត់ធ្ងន់/ប្រមូលផ្តុំនូវគំនិតប្រហាក់ប្រហែលគ្នា

② ផ្សារភ្ជាប់បទពិសោធន៍ផ្ទាល់ខ្លួន ( អ្នកសំរបសំរួល ) ជាមួយអ្នកស្តាប់របស់យើង

③ កំណត់គោលបំណងឱ្យបានច្បាស់លាស់ ( ប្រធានបទ ) ហើយកុំងាករេ

④ ស្វែងរកភាពស្របគ្នារបស់មនុស្ស ដែលផ្សារភ្ជាប់យើងទាំងអស់គ្នា

⑤ រក្សាបែបបទ/មាត្រដ្ឋាន :

ក- ប្រាប់អង្គប្រជុំ ពីអ្វីដែលត្រូវនិយាយ ( សេចក្តីផ្តើម )

ខ- ប្រាប់អង្គប្រជុំ ( តួសេចក្តី )

គ- ប្រាប់អង្គប្រជុំ ពីអ្វីដែលត្រូវបាននិយាយ ( បញ្ចប់/សង្ខេប )



## ១.១១. លំហាត់ពិភាក្សាទៅលើការប្រជុំ

① បទពិសោធន៏កន្លងមក ( វិជ្ជមាន, អវិជ្ជមាន )

② កែប្រែដើម្បីឱ្យមានប្រសិទ្ធិភាពខ្ពស់

ឧទាហរណ៏ :




បន្ទាប់ពីការពិភាក្សាលើបទពិសោធន៏កន្លងមក សូមសរុបនូវលទ្ធផល ដោយឆ្លើយនូវសំនួរដូចខាង ក្រោម :

① តាមបទពិសោធន៏ និងការយល់ឃើញរបស់ក្រុមអ្នក តើហេតុអ្វីបានជាការងារប្រជុំមិនសូវមានប្រសិទ្ធិភាព ហើយមិនអាចទាក់ទាញឱ្យគេចូលរួមបានសកម្ម ?
សូមរាយនូវមូលហេតុ ហើយរៀបជាលំដាប់

② តើក្រុមរបស់អ្នកមានគំនិតយ៉ាងណាដែរ សំរាប់ផ្តល់ជូនសិក្ខាសាលាយកទៅពិចារណា ឬសំរាប់យកទៅអនុវត្តតាម ?
សូមរាយនូវគំនិត បន្ទាប់មករៀបជាលំដាប់
គំនិតដើម្បីឱ្យការងារប្រជុំមានប្រសិទ្ធិភាព ! ! !

## ១.១២. បកស្រាយលទ្ធផលសំយោគទាំងពីរក្រុម :

**មូលហេតុធ្វើឱ្យការប្រជុំមិនសូវមានប្រសិទ្ធិភាព**

១. ពេលវេលាកំណត់ ពុំបានកំណត់ច្បាស់លាស់ និងមិនសមស្រប

២. ភាពក្រីក្ររបស់កសិករ + បញ្ហាពលីថ្កាត់

៣. ទំលាប់របស់កសិករ ( មិនដែលមានប្រយោជន៏ )

៤. បរិយាកាសប្រជុំមិនសមស្រប/មិនអំណោយផល

៥. ការផ្តល់ពត៌មានពុំបានគ្រប់គ្រាន់ និងពុំទាន់ច្បាស់លាស់

៦. ការយល់ឃើញរបស់កសិករ ថាការប្រជុំគ្មានផែនការច្បាស់
៧. ជនដឹកនាំប្រជុំពុំមានឥទ្ធិពល និងប្រជាប្រិយភាព ខ្វះវិធីសាស្ត្រសំរបសំរួល
៨. ខ្វះវិន័យរៀបចំប្រជុំ
៩. ទីកន្លែងមិនសមស្រប
១០. រយៈពេលវែងពេក/ខ្លីពេក
១១. អ្នកចូលរួមខ្វះការទទួលខុសត្រូវ មិនយកចិត្តទុកដាក់ស្តាប់

☞ **ចំណុចដែលធ្វើឱ្យការប្រជុំទទួលបានលទ្ធផលល្អ**

១. កំណត់ពេលវេលាប្រជុំឱ្យបានច្បាស់លាស់ និងសមស្រប
២. កំណត់គោលបំណងប្រជុំឱ្យបានច្បាស់ ( មានកម្មវិធីច្បាស់លាស់ )
៣. ផ្សព្វផ្សាយពត៌មានឱ្យបានទូលំទូលាយ
៤. ការចូលរួមត្រូវមានដំណោះស្រាយសមស្រប ( និយាយឱ្យចំបញ្ហា )
៥. មានផែនការច្បាស់លាស់
៦. កំណត់ទីកន្លែងឱ្យបានច្បាស់លាស់/សមស្រប
៧. ត្រូវបង្កបរិយាកាសពេលប្រជុំ
៨. ថ្លែងអំណរគុណអ្នកចូលរួមប្រជុំ
៩. អ្នកដឹកនាំប្រជុំបង្ហាញពីប្រយោជន៍ដល់អ្នកចូលរួម
១០. បើកទូលាយក្នុងការបញ្ចេញមតិ

## ១.១៣. ប្រភេទប្រជុំសំរាប់ការងារអភិវឌ្ឍន៍ភូមិ

→ ប្រជុំដើម្បីផ្លាស់ប្តូរពត៌មាន បទពិសោធន៍
→ ប្រជុំដើម្បីរៀបចំផែនការ ( ឧទា. សិក្ខាសាលាធ្វើផែនការអភិវឌ្ឍន៍ភូមិ ) ដោយមានអ្នកឯកទេសជួយផ្តល់យោបល់ ឬសំរបសំរួល
→ ប្រជុំដើម្បីត្រួតពិនិត្យវាយតំលៃការរីកចំរើននៃផែនការ

ប្រជុំសំរេចជ្រើសរើសតំណាងក្រុម ឬគណៈកម្មការអភិវឌ្ឍន៍ភូមិ

## ១.១៤. ការប្រជុំសំរាប់ការងារអភិវឌ្ឍន៍ភូមិ

① និយាយ-បញ្ចេញយោបល់

→ ② ឮបានច្បាស់ ?

→ ③ យល់បានច្បាស់ ?

→ ④ យល់ព្រមតាម ?

→ ⑤ សំរេចជាផ្លូវការ ?

→ ⑥ អនុវត្តតាម?

→ ⑦ សំរេច ?

ពេលប្រជុំចប់ យើងព្យាយាមឆ្លើយនូវសំនួរពី ①→ ⑤ ! ចំណុច ⑥ ⑦ ... សំរាប់តាមដាន

⇨ អ្វីដែលយើងគួរយល់ដឹងសំរាប់យកទៅអនុវត្ត ការអនុវត្តក្នុងការរៀបចំការងារប្រជុំ

គោលបំណង ខ្លឹមសារច្បាស់លាស់

- ការផ្តល់ពត៌មាន ទាក់ទងប្រជុំច្បាស់លាស់
- ពេលវេលាសំរាប់ត្រៀម រៀបចំឱ្យបានគ្រប់គ្រាន់
- បរិមាណអ្នកចូលរួម
- ពេលវេលាដែលត្រូវប្រជុំ
- រយៈពេលប្រជុំម្តងៗ
- ទីកន្លែងប្រជុំ
- ការទទួល និងបរិយាកាសទូទៅ
- សាច់ការ និងបរិយាកាសរីករាយ + ល័ក្ខខ័ណ្ឌសំរាប់ឱ្យបញ្ចេញយោបល់
- មធ្យោបាយ-ឧបករណ៍ សំភារៈផ្សេងៗ សំរាប់ជួយសំរបសំរួល
- ប្រភេទអ្នកចូលរួម ( ភេទ, អាយុ, ចំណេះដឹង ចំណាប់អារម្មណ៍)
- ប្រភេទអង្គប្រជុំ វាគ្មិនដែលចូលរួម

- ការតាមដាន ឬពិនិត្យឡើងវិញនូវអ្វីដែលបានសំរេចក្នុងអង្គប្រជុំ ។ល។

## ១.១៥ ការសំរេចចិត្ត

តើយើងធ្វើការសំរេចចិត្តយ៉ាងដូចម្តេច ?

- ការយោគយល់គ្នាដោយមិនបាច់បោះឆ្នោត
- តាមរយៈការបោះឆ្នោត

គោលការណ៍នៃការបោះឆ្នោត មានច្រើនប្រភេទ :

→ ៥០ + ១

→ ២/៣ : មានតាមសភា

→ ៣/៤ : កំរមាន

→ ៨៥%

→ ១០០% : សាសនា ( ឧទា. បោះឆ្នោតជ្រើសរើសមេសាសនា សម្តេចសង្ឃរាជ ប៉ូប )

## ១.១៦. កំណត់ហេតុផ្លូវការត្រូវមាន :

១. ទីកន្លែង

២. កាលបរិច្ឆេទ

៣. សមាសភាពចូលរួម + បញ្ជីវត្តមាន + ហត្ថលេខា

៤. របៀបវារៈ/ខ្លឹមសារ

៥. គោលបំណង

៦. លទ្ធផល ( ក្រោយពីប្រជុំចប់បានសំរេចអ្វី ? )

៧. ឈ្មោះប្រធានអង្គប្រជុំ

៨. អ្នកកត់ត្រា

៩. ពេលវេលាប្រជុំ

១០. ថ្ងៃ ខែ ធ្វើកំណត់ហេតុចប់ជាផ្លូវការ

១១. ផ្ញើជូនឱ្យគណៈកម្មការពិនិត្យ ( កែលំអ )

១២. បញ្ជូនឱ្យអ្នកកត់ត្រាកែកំហុស

១៣. ពិនិត្យ ចុះហត្ថលេខាទទួលស្គាល់ផ្លូវការ ! ! !

**ឧទាហរណ៍ :**

- កាលបរិច្ឆេទ : ២៨/១០/៩៩
- ម៉ោង : ៨:០០-៩:០០
- ទីកន្លែង : សាលាស្រុក
- សមាសភាពអ្នកចូលរួម : ២៣ នាក់
- ប្រធានអង្គប្រជុំ : លោក ម៉េវ
- ខ្លឹមសារ ( របៀបវារៈ )

១) ពត៌មានទាក់ទងនឹងការចុះមកស្រាវជ្រាវរបស់អង្គការប្រឆាំងគ្រោះអត់ឃ្លាន

២) ធ្វើការពិភាក្សាបែងចែកអង្ករ ៥ គ្រួសារ ដើម្បីជីកស្រះ

លទ្ធផល

១) គណៈកម្មការនឹងជួយប្រាប់ប្រជាជនឱ្យដឹងរឿងរ៉ាវនេះ

២) ឱ្យគ្រួសារពូ ក. ខ. គ. ឃ. ង បើកអង្ករដើម្បីជីកស្រះ

- ហត្ថលេខា និងឈ្មោះអ្នកកត់ត្រា

# II. ផែនការអភិវឌ្ឍន៍ភូមិ

ធ្វើផែនការ ដោយមានការចូលរួមពីប្រជាជនតាមមូលដ្ឋាន ឬពីភូមិ :

- អភិវឌ្ឍន៍តាមមូលដ្ឋាន
- ការចូលរួមពីប្រជាជន
- ការធ្វើផែនការអភិវឌ្ឍន៍

## ២.១. ការអភិវឌ្ឍន៍ :

① អ្វីទៅជាការអភិវឌ្ឍន៍តាមមូលដ្ឋាន ?

② ហេតុអ្វីបានជាការអភិវឌ្ឍន៍តាមមូលដ្ឋាន ទាមទារឱ្យមានការចូលរួមពីប្រជាជន ?

③ ហេតុអ្វីបានជាមានអង្គការចុះមកជួយអភិវឌ្ឍន៍ភូមិ ? គេបានថវិកាមកពីណា ?

④ តើការចុះមកជួយរបស់អង្គការមានរយៈពេលយូរអង្វែងឬទេ ? ហេតុអ្វី

⑤ តើអង្គការដកចេញពីភូមិនៅពេលណា ?

⑤ តើប្រជាជនតាមមូលដ្ឋាន ឬអ្នកភូមិចង់រៀបចំយ៉ាងណាដែរ ដើម្បីធានាថាអ្វីដែលអង្គការបានជួយ អាចរក្សាបានយូរ ឬអាចរីកចំរើនបានច្រើនថែមទៀត ?

### ១. អភិវឌ្ឍន៍

- ក្រ → មាន
- មិនចេះ → ចេះ
- មិនប្រសើរ → ប្រសើរ
- មិនល្អ → ល្អ

ការអភិវឌ្ឍន៍មាន ៤ សំខាន់ៗ គឺ :

→ ឱ្យ ឬចែកអំណោយ ( ជួយសង្គ្រោះបន្ទាន់)

→ ធ្វើអ្វី ឬសាងសង់អ្វីឱ្យ ( ឧទាហរណ៍ : សង់សាលារៀន ស្ពាន ថ្នល់)

→ ធ្វើអ្វីមួយជាមួយប្រជាជនដោយប្រជាជនចូលរួមនូវគំនិតយោបល់ ការទទួលខុសត្រូវ និងសំភារៈ

→ ប្រជាជនតាមមូលដ្ឋានជាអ្នករៀបចំឱ្យមានការអភិវឌ្ឍន៍ដោយខ្លួនឯង

២. ព្រោះថា

- ប្រជាជនដឹងពីតម្រូវការរបស់ខ្លួន




**៣. ហេតុអ្វីមានអភិវឌ្ឍន៍ភូមិ បានថវិកាពីណា ?**

- បំបាត់ភាពក្រីក្រ
- ថវិកាបានពីប្រទេសអ្នកមាន ដែលប្រជាជនគេបរិច្ចាគ តាមរយៈអំពើសប្បុរសធម៌

**៤. ការអភិវឌ្ឍន៍របស់អង្គការ**

- ជួយឱ្យយើងជួយដោយខ្លួនឯង
- ជួយបន្តិចម្តងៗ ដល់ដំណាក់កាលមួយនឹងដកចេញ
- ជួយរៀបចំឱ្យប្រជាជាពលរដ្ឋត្រៀមធ្វើការងារដោយខ្លួនឯង

**៥. អង្គការដកចេញនៅពេល**

- ចប់ភារកិច្ច ដោយឱ្យសមិទ្ធិផលនេះនៅបន្តរហូត

**៦. គឺមានតែប្រជាជនមូលដ្ឋាន និងរដ្ឋអំណាចទេដែលដើរតួនាទីសំខាន់ក្នុងបញ្ហានេះ**

## ២.២. ដំណើរការនៃការរៀបចំផែនការ :

① ពិនិត្យឡើងវិញនូវបំរែបំរួលដែលមានកន្លងមក ឆ្លងតាមរយៈការមើលឃើញ ឬ

→ តើកន្លងមក មានបំរែបំរួលអ្វីខ្លះ ? អ្វីខ្លះជាបំរែបំរួលវិជ្ជមាន ? អ្វីខ្លះជាបំរែបំរួលអវិជ្ជមាន ?

**វិធីសាស្ត្រ** : ធ្វើការប្រជុំពិភាក្សាជាក្រុម ដើម្បីប្រមូលផ្តុំនូវគំនិត មតិរបស់អ្នករស់នៅក្នុងភូមិ

② អ្វីទៅជាបញ្ហាដែលកំពុងកើតមានឡើង ? អ្វីទៅជាឫសគល់ ឬហេតុផលនៃបញ្ហាទាំងនេះ ? អ្វីទៅជាបញ្ហាចំបងដែលយើងត្រូវដោះស្រាយ ឬទាមទារឱ្យមានការដោយស្រាយជាបន្ទាន់ ?

**វិធីសាស្ត្រ** : ធ្វើការពិភាក្សាជាក្រុម ដើម្បីរាយនូវបញ្ហា បន្ទាប់មក កំណត់នូវអាទិភាព មានន័យថាអ្វីទៅជាបញ្ហាចំបង១ ហើយអ្វីទៅជាឫសគល់នៃបញ្ហាទាំងនេះ ( ដើមឈើនៃបញ្ហា ) ។

③ អ្វីទៅជាទស្សនៈរបស់យើងសំរាប់រយៈពេលទៅថ្ងៃមុខ ( ឧទាហរណ៍ ១ ឆ្នាំ ២ ឆ្នាំ ៣ ឆ្នាំ ... ទៅខាងមុខ ) មានន័យថា អ្វីដែលយើងប្រាថ្នាចង់បាន ឬរឹងដែលកើតមានឡើងក្នុងរយៈពេល ១ ឆ្នាំ ឬ ២ ឆ្នាំ ឬ ៣ ឆ្នាំ ...

**វិធីសាស្ត្រ** : ធ្វើការពិភាក្សា ឬប្រជុំពិភាក្សាជាក្រុម ដោយម្នាក់១ បញ្ចេញនូវទស្សនៈរបស់ខ្លួន ។ បន្ទាប់មក ពិភាក្សាគ្នា តើយើងអាចសំរេចបានឬទេ ?

④ តើយើងអាចធ្វើអ្វីខ្លះ ? ហើយយើងអនុវត្តយ៉ាងដូចម្តេច ដើម្បីឱ្យបានសំរេចនូវទស្សនៈរបស់យើង ?

**វិធីសាស្ត្រ** : រាយនូវសកម្មភាពចំបង១ ដើម្បីអាចឱ្យយើងសំរេចបាននូវសេចក្តីប្រាថ្នា ឬការរំពឹងទុករបស់យើង ។ បន្ទាប់មកពិភាក្សាគ្នា តើយើងអាចធ្វើបានឬទេ ? យើងធ្វើ ឬអនុវត្តយ៉ាងដូចម្តេច ?

⑤ តើយើងត្រូវការធនធានអ្វីខ្លះ ដើម្បីអាចធានាឱ្យយើងសំរេចបាននូវការគ្រោងទុករបស់យើង ? តើធនធានអ្វីខ្លះដែលយើងមានស្រាប់ ? ធនធានអ្វីខ្លះដែលយើងអាចរកបាន ? ធនធានអ្វីខ្លះដែលយើងត្រូវការពីខាងក្រៅ ( ឧទាហរណ៍ អង្គការក្រៅរដ្ឋាភិបាល សមាគមផ្សេង១ អង្គការរដ្ឋ ។ល។ ) ?

⑥ បែងចែកនូវការទទួលខុសត្រូវ មានន័យថា អ្នកណាធ្វើអ្វី ? យើងត្រូវការមនុស្សប៉ុន្មាននាក់ ? នរណាទទួលខុសត្រូវលើអ្វី ?

⑦ រៀបចំតារាងផែនការសកម្មភាព ដោយកំណត់ឱ្យបានច្បាស់

- អ្វីដែល ( ត្រូវ ) ធ្វើឱ្យបានសំរេច
- សកម្មភាព ឬជំហានសំខាន់ៗ
- ពេលវេលា
- ទីកន្លែង
- អ្នកទទួលខុសត្រូវ

**កំណត់សំគាល់ :**

⇨ ចំណុចពី ① ដល់ ⑦ ជាចំណុចណែនាំសំរាប់ជំហានសំខាន់ៗ ក្នុងការអនុវត្តនីការរៀបចំផែនការអភិវឌ្ឍន៍ភូមិ ឬមូលដ្ឋានរបស់យើង ។ យើងអាចធ្វើការកែប្រែទៅតាមតំរូវការ ឬស្ថានភាពជាក់ស្តែងរបស់ យើង ពេលអនុវត្តការប្រជុំរៀបចំផែនការរបស់ភូមិយើង ។ ក្នុងការរៀបចំផែនការ ឬគំរោងការ យើងតែង តែពិភាក្សាគ្នាលើចំណុចទាក់ទងការវាស់វែងនូវលទ្ធផលនៃការប្រឹងប្រែងរបស់យើង ក្នុងការអនុវត្តនីគំរោង ការ ។ មានន័យថា អ្វីទៅជាគ្រឿងសំគាល់ ឬសន្ទស្សន៍សំរាប់វាស់នូវលទ្ធផលនៃការងារ ហើយយើងវាស់វែងវាយ៉ាងដូចម្តេច ?

⇨ ក្នុងដំណើរការរៀបចំគំរោងការ យើងត្រូវធានានូវល័ក្ខខ័ណ្ឌដែលផ្តល់លទ្ធភាពដល់ការចូលរួមពីប្រជាជន ឬតំណាងរបស់ភូមិ ។ ការចូលរួមសំខាន់ណាស់ ពីព្រោះគាត់អាចដឹងច្បាស់ថា បញ្ហាអ្វីដែលយើងត្រូវដោះ ស្រាយរួមគ្នា ? ដោះស្រាយយ៉ាងដូចម្តេច ? ការចូលរួមធានាឱ្យអ្នកភូមិមានអារម្មណ៍ថា គាត់ជាអ្នកចូលរួម ចំណែក ឬជាម្ចាស់របស់គំរោង ។ ភាពជាម្ចាស់នៃគំរោង ជាកត្តាមួយយ៉ាងសំខាន់ ដើម្បីធានានូវជោគជ័យ របស់គំរោងការ ឬផែនការអភិវឌ្ឍន៍របស់យើង ! !

## ២.៣. ប្រភេទនៃការចូលរួមក្នុងការងារអភិវឌ្ឍន៍ភូមិ :

① ភ្នាក់ងារអភិវឌ្ឍន៍មកផ្តល់ពត៌មានដល់អ្នកភូមិ តើគេមានគំរោងធ្វើអ្វីខ្លះនៅតាមភូមិ ( គេគ្រាន់តែផ្តល់ពត៌មានឱ្យយើង ហើយភ្នាក់ងារអភិវឌ្ឍន៍ ជាអ្នកសំរេចលើអ្វីៗ ទាំងអស់ )

② ភ្នាក់ងារអភិវឌ្ឍន៍ បង្ហាញអំពីគំរោងការអភិវឌ្ឍន៍ភូមិដល់អ្នកភូមិ ហើយសុំយោបល់ពីអ្នកភូមិ ។ គេអាចយកយោបល់មកពិចារណា ដើម្បីធ្វើការកែសំរួល ( តែជួនកាលក៏គេមិនកែសំរួលដែរ ។

③ ភ្នាក់ងារអភិវឌ្ឍន៍ ចុះធ្វើការសិក្សាស្វែងយល់ពីស្ថានភាព និងតំរូវការរបស់ភូមិ ។ បន្ទាប់មក គេយកពត៌មាននេះមកប្រើប្រាស់ជាមូលដ្ឋាន សំរាប់រៀបចំគំរោងការអភិវឌ្ឍន៍ ( អ្នកភូមិជាអ្នកផ្តល់ពត៌មាន ភ្នាក់ងារអភិវឌ្ឍន៍ ជាអ្នកសំរេច )

④ ភ្នាក់ងារអភិវឌ្ឍន៍ និងអ្នកភូមិ ធ្វើការពិភាក្សា វិភាគលើស្ថានភាព តំរូវការ និងដំណោះស្រាយក៏ដូចជា មធ្យោបាយដោះស្រាយទាំងអស់គ្នា ។ ( ភ្នាក់ងារអភិវឌ្ឍន៍ និងអ្នកភូមិ ជាអ្នកសំរេចទាំងអស់គ្នា )

⑤ អ្នកភូមិធ្វើការពិភាក្សា វិភាគលើស្ថានភាព តំរូវការ និងមធ្យោបាយដោះស្រាយ ដោយមានភ្នាក់ងារអភិវឌ្ឍន៍ ជាអ្នកសំរបសំរួល ។ ( អ្នកភូមិជាអ្នកសំរេច ដោយមានការជួយសំរបសំរួលពីភ្នាក់ងារអភិវឌ្ឍន៍ )

⑥ អ្នកភូមិធ្វើការពិភាក្សា វិភាគលើស្ថានភាព តំរូវការ និងមធ្យោបាយដោះស្រាយ ដោយខ្លួនឯង ។ បន្ទាប់មក អ្នកភូមិរៀបចំនូវគំរោងអភិវឌ្ឍន៍ភូមិ ហើយបញ្ជូនមកភ្នាក់ងារអភិវឌ្ឍន៍ ឬស្ថាប័នផ្សេងៗ ដើម្បីសុំជំនួយខ្លះៗ មកពីខាងក្រៅតាមភាពចាំបាច់ ។

## ២.៤. ការបង្កើតគំនិតសំរាប់ការរៀបចំគំរោងអភិវឌ្ឍន៍ភូមិ :

**បំរែបំរួលកន្លងមក ?**

( អ្វីទៅជាបំរែបំរួលវិជ្ជមាន ឬបំរែបំរួលមានការរីកចំរើន ?  អ្វីទៅជាបំរែបំរួលអវិជ្ជមាន ឬបំរែបំរួល ដែលនាំមកនូវបញ្ហាឱ្យមកយើង ?  ឬអ្វីទៅជាបញ្ហាដែលចេះតែធ្ងន់ធ្ងរជាងមុន ? )

(−)  (-)

តើអ្វីខ្លះជាបំរែបំរួលដែលយើងប្រាថ្នាចង់បាន ក្នុងរយៈពេលខាងមុខ ( ឧទាហរណ៍ ១ ឆ្នាំ  ២ ឆ្នាំ ឬ ៣ ឆ្នាំ ... ទៅមុខទៀត)

តើយើងត្រូវតែធ្វើអ្វីខ្លះ ដើម្បីឱ្យបានសំរេចនូវអ្វីដែលយើងប្រាថ្នាឱ្យបានសំរេចនោះ
គំរោងអភិវឌ្ឍន៍ ឬសកម្មភាពសំខាន់ៗ ទាំងឡាយ ដើម្បីអាចឱ្យយើងសំរេចបាននូវបំរែបំរួលដែល យើងប្រាថ្នាចង់បាន

## ២.៥. ណែនាំ/សន្ទួលសំខាន់

① រាយបំរែបំរួល (+) រីកចំរើន និង (−) មិនរីកចំរើន/បញ្ហាធ្ងន់ធ្ងរ

② ស្រង់យកបញ្ហា ៣ សំខាន់ៗ វិភាគនូវ:

- ហេតុផល
- មូលហេតុ
- ឫសគល់

③ អ្វីដែលយើងប្រាថ្នាចង់បានសំរេចនៅពេលមួយឆ្នាំខាងមុខ

④ រាយនូវសកម្មភាពការងារសំខាន់ៗ សំរាប់ជួយឱ្យយើងសំរេចនូវក្តីប្រាថ្នារបស់យើង (ពិតប្រាកដ កុំស្រមើស្រមៃ)

ក្រោយពីពិភាក្សា យើងបានលទ្ធផលដូចខាងក្រោម :

**ក្រុមទី ១**

⊕ **បំរែបំរួលវិជ្ជមាន**

- តាមភូមិមានពេទ្យសត្វ
- មានផ្លូវពីរ
- មានស្ពាន
- តាមភូមិមានអណ្តូងទឹកស្អាត
- មានសាលារៀនថ្មី
- មានស្រះតាមគ្រួសារ និងតាមភូមិ
- ប្រជាជនចេះសំរាន្តក្នុងមុង
- ប្រជាជនចេះបរិភោគបន្លែដែលដាំ
- ប្រជាជនយល់ពីការថែទាំសុខភាព
- លំនៅដ្ឋានប្រសើរជាងមុន

⊖ **បំរែបំរួលអវិជ្ជមាន**

- បរិមាណគោក្របីថយចុះជារៀងរាល់ឆ្នាំ
- ប្រជាជនមិនសូវចូលរួមប្រជុំ
- តាមភូមិគ្មានបង្គន់អនាម័យ
- ផ្លូវថ្នល់រិចរិលជាលំដាប់
- អណ្តូងស្នប់ខូចគ្មានលទ្ធភាពជួសជុល
- ប្រព័ន្ធធារាសាស្ត្រខូចខាត
- ការសិក្សារបស់កុមារត្រូវថយចុះ
- សណ្តាប់ធ្នាប់សង្គមមិនទាន់ប្រសើរ
- មូលដ្ឋានដាច់ស្រយាល ខ្វះសាលារៀន
- ភាពអត់ឃ្លានកើតឡើងរាល់ឆ្នាំ

→ **វិភាគមូលហេតុ**

✳ ភាពអត់ឃ្លាន

- ខ្វះកំលាំងពលកម្ម/អូសទាញ
- ប្រជាជនខិតខំបង្កបង្កើនផល
- ខ្វះគំនិតទុកដាក់ និងសន្សំសំចៃ
- គ្រោះធម្មជាតិ
- ដីដាំដុះតូច
- កូនច្រើន

✳ ផ្លូវខូចខាត

- ប្រជាជនមិនជួយថែទាំ
- ប្រជាជនទាមទារស្បៀងពលកម្មក្នុងការជួសជុល
- រទេះគោ/គោ-ក្របីដើរជាន់រាល់ថ្ងៃ
- គ្រោះធម្មជាតិ
- ខ្វះប្រឡាយរំដោះទឹក

→ **ការចង់សំរេចក្តីប្រាថ្នាមួយឆ្នាំខាងមុខ**

- មានផ្លូវសមរម្យ ( ស្ពាន លូ )
- មានទឹកប្រើប្រាស់ ( អណ្តូងស្នប់ ស្រះទឹក )
- ធានាបាននូវសន្តិសុខសង្គម
- មានបង្គន់អនាម័យ

→ ***សកម្មភាពការងារសំខាន់ៗ សំរាប់ជួយឱ្យសំរេចនូវក្តីប្រាថ្នា***

•• មានផ្លូវសមរម្យ

- គណៈកម្មការអភិវឌ្ឍន៍ភូមិប្រជុំរៀបចំផែនការ
- កំណត់ពេលចាប់ផ្តើម និងបែងចែកការងារគ្រប់គ្រងកំលាំងពលកម្ម
- ត្រៀមសំភារៈឱ្យបានគ្រប់គ្រាន់

•• ដើម្បីធានានូវសន្តិសុខសង្គម

- សាងសង់រោងយាមកាម
- ធ្វើតារាងបែងចែកក្រុម
- ធ្វើសំណើដល់អាជ្ញាធរដើម្បីជាជំហឹង
- កំណត់វិន័យក្នុងការអនុវត្តន៍ផែនការ

ក្រុមទី ២

**(+) បំរែបំរួលវិជ្ជមាន**

- សន្តិសុខទូទៅ
- សន្តិសុខស្បៀងល្អប្រសើរ
- យល់ដឹងបញ្ហាថែទាំសុខភាព
- វិស័យអប់រំ
- បច្ចេកទេសកសិកម្ម
- ផ្លូវថ្នល់ប្រសើរជាងមុន

**(-) បំរែបំរួលអវិជ្ជមាន**

- ជំងឺគ្រុនចាញ់កើនឡើង
- សត្វព្រៃថយចុះ + ព្រៃឈើ
- ខ្វះស្មារតីចូលរួមជាមួយកម្មវិធីអភិវឌ្ឍន៍
- វិស័យអប់រំនៅខ្វះខាត
- វិស័យមធ្យោបាយដឹកជញ្ជូននៅពុំទាន់ល្អប្រសើរ
- ការអភិវឌ្ឍន៍មិនទាន់ចំទិសដៅ
- ភាពក្រីក្រពុំទាន់បានជួយទំនុកបំរុង + កែលំអ
- គ្រប់វិស័យទាំងអស់ពុំទាន់រីកចំរើន
- អណ្តូងទឹក ( អណ្តូងស្នប់ ) គ្មានគុណភាព

→ **បញ្ហាសំខាន់ៗ ដែលយកមកដោះស្រាយ**

- ជំងឺគ្រុនចាញ់
- ភាពក្រីក្រពុំទាន់បានជួយទំនុកបំរុង

✳ **ឫសគល់នៃជំងឺគ្រុនចាញ់**

១. ដេកពុំចងមុង + ការរស់នៅពុំស្អាត

២. ខ្វះថ្នាំព្យាបាល

៣. ទំនៀមទំលាប់

៤. ផ្លាស់ប្តូរទីកន្លែង នាំចូលជំងឺឆ្លង

៥. ខ្វះស្មារតីប្រុងប្រយ័ត្នជំងឺឆ្លង ( ការពារ )

→ **អ្វីដែលយើងចង់បាននៅ ១ ឆ្នាំ ខាងមុខ :**

- ផ្លូវគមនាគមន៍ល្អ ឬល្អជាងមុន
- ទឹកស្អាត ឬប្រភពទឹកគ្រប់គ្រាន់
- ជីវភាពល្អប្រសើរ
- សាលារៀនគ្រប់គ្រាន់

- បំបាត់ ឬកាត់បន្ថយជំងឺឆ្លង
- ជួយរកមុខរបរឱ្យដល់អ្នកក្រីក្រ
- ជំនួយឥណទាន

→ **សកម្មភាព និងធនធានសំខាន់ៗ ដើម្បីសំរេចក្តីប្រាថ្នា**

- កំលាំងពលកម្មប្រជាជន
- សំភារៈផ្សេងៗ
- ធនធានពីក្រៅ
- គណៈកម្មការភូមិ + ឃុំ + រដ្ឋអំណោចមូលដ្ឋាន និងអ្នកចូលរួមដទៃ
- អ្នកចូលរួម ២០០ នាក់ សំរាប់ ២៥-៣០ ថ្ងៃ

∗ **ឫសគល់នៃភាពក្រីក្រ**

- កូនច្រើន
- អវិជ្ជា (ជឿលើព្រេងសំណាង)
- ខ្ជិលច្រអូស
- ខ្វះទុន
- តំបន់ដាច់ស្រយាល
- មកពីសង្គ្រាម

## ២.៦. ប្រភេទនៃការចូលរួមដែលយើងកំពុងអនុវត្ត

① ស្វែងយល់ពីស្ថានភាព តំរូវការ និងរៀបចំគំរោងអភិវឌ្ឍន៍

⇓

② រៀបចំគំរោងអភិវឌ្ឍន៍ជាមួយគ្នា

⇓

③ អ្នកភូមិជាអ្នករៀបចំគំរោងអភិវឌ្ឍន៍ដោយខ្លួនឯង

## ២.៧. បីសំនួរទាក់ទងនឹងផែនការ

១) ហេតុអ្វីបានជាចាំបាច់ធ្វើផែនការ ?

- ចង់ធ្វើអ្វីមួយក្នុងរយៈពេលកំណត់មួយ
- មានគោលបំណងអ្វីមួយ

២) ហេតុអ្វីបានជាពេលធ្វើផែនការ យើងត្រូវឱ្យមានការចូលរួមពីមនុស្សច្រើនគ្នា ?

- សំរេចទាំងអស់គ្នា
- ឯកភាព
- ទទួលខុសត្រូវ
- មានភាពជាកម្មសិទ្ធិ
- ផ្តុំគំនិតច្រើន

៣) ហេតុអ្វីបានជាពេលមានការប្រជុំធ្វើផែនការ យើងត្រូវការពេលច្រើន ?

- ដើម្បីឱ្យសព្វជ្រុងជ្រោយ
- វិភាគបញ្ហាបានច្រើន

**ការបង្កើតនូវទស្សនៈសំរាប់អនាគត (Vision)**



ស្ថានភាព
បច្ចុប្បន្ន

អ្វីដែលយើងរំពឹងទុកថានឹងកើតមាន
ក្នុងរយៈពេលមួយឆ្នាំ ឬពីរឆ្នាំក្រោយមក
បំរែបំរួលដែលយើងចង់បាន ! ! !

**ត្រៀមលក្ខណៈសំរាប់អនាគតដើម្បីសំរេច**

## មួយឆ្នាំក្រោយមកតើយើងនឹងបានសំរេច



ការកំណត់ទិសដៅឱ្យបានច្បាស់

- បញ្ជាក់ឱ្យបានច្បាស់អ្វីដែលយើងចង់ធ្វើឱ្យបានសំរេច
- កំណត់នូវបរិមាណ ឬខ្នាតជាក់លាក់ដែលអាចវាស់វែងបាន
- អ្វីដែលយើងបានកំណត់ត្រូវឱ្យមានលក្ខណៈសមស្រប ហើយប្រាកដជាអាចធ្វើបាន
- កំណត់ឱ្យបានច្បាស់លាស់នូវពេលវេលា ឬរយៈពេលដែលត្រូវធ្វើឱ្យបានសំរេច

### ការបង្កើតគំនិត/ទស្សនៈជាក់លាក់ និងទិសដៅសំរាប់អនាគតត្រូវសំអាងលើ

១. បទពិសោធន៍កន្លងមកមានយ៉ាងណាខ្លះ ?

២. សមត្ថភាពរបស់យើងមានត្រឹមទំហំណាដែរ ?

៣. តើរដ្ឋអំណាចតាមមូលដ្ឋានអាចជួយយើងបានត្រឹមកំរិតណាដែរ ?

៤. តើយើងអាចសង្ឃឹម ឬរំពឹងថាអង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិផ្សេងៗ អាចជួយយើងបានកំរិតណាដែរ ?

៥. តើទំហំនៃការជួយពីសប្បុរសជនផ្សេងៗ មានប៉ុន្មានដែរ ?

→ សំនួរ : គណៈកម្មការខ្លួនទទេ តើធានាឬទេ ?

ចំលើយ : ត្រូវមានមូលនិធិ និងការសំរេចចិត្ត ( កញ្ចប់ថវិកា ) សំរាប់រចនាសម្ព័ន្ធ បើមិនអញ្ចឹងទេ និងទទួលបរាជ័យ ។

### ក្បួនសំរាប់ជួយសំរួលដល់ការពិភាក្សា

១. ម្នាក់ៗ បញ្ចេញនូវគំនិត ឬមតិរបស់ខ្លួនយ៉ាងខ្លី ហើយច្បាស់

២. វាយគំនិតនេះលើក្ដារខៀន ឬផ្ទាំងក្រដាសស

៣. ពិភាក្សាលើគំនិតដែលលើកឡើង ឬថែមថយនូវគំនិតដែលលើកឡើង

៤. សរុបនូវលទ្ធផលនៃការពិភាក្សា

## ២.៨. ការវិភាគបញ្ហាតាមរបៀបដើមឈើ

- បញ្ហាដែលត្រូវវិភាគ : ដើម
- មូលហេតុដែលនាំឱ្យមានបញ្ហា : ឫស
- ផលវិបាកដែលបង្កឡើងដោយបញ្ហា : មែក ធាង ស្លឹក ផ្កា ផ្លែ

→ បញ្ហាដែលត្រូវវិភាគ : ជំងឺគ្រុនចាញ់

→ មូលហេតុដែលនាំឱ្យមានបញ្ហា :

- ខ្វះមុខរបរ
- ហូបមិនគ្រប់គ្រាន់
- គ្មានថ្នាំព្យាបាល
- ព្រៃជុំវិញផ្ទះ
- មិនទំលាប់ដេកមុង
- មិនជឿថាមានជំងឺគ្រុនចាញ់
- ខ្វះទឹកឆ្អិន
- ថ្លុកជុំវិញផ្ទះ
- មូសដែកគោលញី
- អត់មុង
- អត់លុយទិញ

→ ផលវិបាកដែលបង្កឡើងដោយបញ្ហា :

- សៅហ្មង
- សុខភាពទ្រុឌទ្រោម
- អន់ប្រាជ្ញា
- ខាតពេល

**ជំហានសំខាន់ៗសំរាប់រៀបចំផែនការ :**



សមាគមកសិករចំរើនផលពីធម្មជាតិភូមិរំពាក់ពេន

ស.ក.ច.ធ ភូមិរំពាក់ពេន

លក្ខន្តិកៈសមាគម

# កសិករចំរើនផលពីធម្មជាតិភូមិរំពាក់ពេន



រៀបរៀងដោយកសិករភូមិរំពាក់ពេន

# សញ្ញាសំគាល់ សមាគមកសិករប៉ីរែងផលកិច្ចជាតិភ្នំពោកំពេង

ស.ក.ច.ជ ភ្នំពោកំពេង

# លក្ខន្តិកៈសមាគមកសិករចំរើនផលពីធម្មជាតិភូមិរំពាក់ពេន
## ឃុំឧត្តមសូរិយា ស្រុកត្រាំកក់
## ខេត្ត តាកែវ

បុព្វហេតុ :

ដោយយល់ឃើញថាប្រជាកសិករនៅភូមិ រំពាក់ពេន ឃុំ ឧត្តមសូរិយា រស់នៅជាលក្ខណៈគ្រួសារ (ឯកជន) ប្រកបមុខរបរកសិកម្មពុំសូវមានការរីចំរើនជាវិជ្ជមាន ជួបប្រទេះនូវការខ្វះខាតទុន កង្វះលទ្ធភាពក្នុងការកសាងមុខរបរ។ ហើយម្យ៉ាងវិញទៀតដោយសារមានការកើនឡើងនូវការប្រើប្រាស់ធនធានពីខាងក្រៅជាពិសេសជីគីមីនិងធនធានធម្មជាតិចេះតែបាត់បង់ពីមួយឆ្នាំទៅមួយឆ្នាំនោះទើបមានកសិករមួយក្រុមបានផ្តួចផ្តើមបង្កើតជាក្រុមសមាគមនេះឡើងដោយមានការសំរបសំរួល ពីអង្គការសេដាក។ សមាគមនេះបង្កើតជាផ្លូវការនៅ ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៤ ដែលមានសមាជិកសរុប១៩ នាក់ ស្រី ២នាក់នៅ ក្នុងភូមិរំពាក់ពេន ឃុំឧត្តមសូរិយា ស្រុកត្រាំកក់ ខេត្តតាកែវ ។

### ជំពូក ១
### អត្តសញ្ញាណរបស់សមាគម

ប្រការ ១ :ឈ្មោះសមាគមកសិករ

ឈ្មោះសមាគមជាផ្លូវការគឺសមាគមកសិករចំរើនផលពីធម្មជាតិភូមិរំពាក់ពេន

ប្រការ ២:លក្ខណៈសំគាល់របស់សមាគម

សមាគមនេះឯករាជ្យមិនពាក់ព័ន្ធនយោបាយមិនមែនជារបស់រដ្ឋាភិបាលឬគណៈបក្សណាមួយឡើយនិងមិននៅក្រោមការគ្រប់គ្រងរបស់អង្គការ ឬស្ថាប័នណាមួយទេ ។

សញ្ញាសំគាល់របស់សមាគមមានរូបផ្លែឪឡឹកនិងត្រសក់ដោយមានអមគួរស្រូវនៅក្នុងស្លឹកពោធិ៍។

ប្រការ ៣ :ទីតាំងរបស់សមាគម ស្ថិតនៅភូមិ រំពាក់ពេន ឃុំឧត្តមសូរិយា ស្រុកត្រាំកក់ ខេត្តតាកែវ ។

### ជំពូក ២
### គោលបំណង និងសកម្មភាព

ប្រការ ៤ : គោលបំណង

- សន្សំទុនសំរាប់សមាជិកនៅក្នុងក្រុមសំរាប់ប្រើប្រាស់
- ពង្រឹងការអនុវត្តន៍កសិកម្មតាមគោលការណ៍ធម្មជាតិ
- ចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ
- កាត់បន្ថយការខ្ចីការប្រាក់ពីក្រៅដែលមានអត្រាការប្រាក់ខ្ពស់

- ផ្សព្វផ្សាយបច្ចេកទេសកសិកម្មនិងអភិវឌ្ឍន៍កសិកម្មតាមគោលការណ៍ធម្មជាតិ
- រក្សាធនធានធម្មជាតិ ព្រៃឈើ ត្រី និងការដាំដុះឡើងវិញ

ប្រការ ៥ : សកម្មភាពរបស់សមាគម

- សន្សំប្រាក់ និងចងការប្រាក់
- ការប្រជុំប្រចាំខែ និងបណ្តុះបណ្តាលកសិកម្ម
- អភិរក្ស និងកែលំអរធនធានធកម្មជាតិ
- ធ្វើកសិកម្មតាមគោលការណ៍ធម្មជាតិ
- រៀបចំសូនដំណាំគ្រប់រដូវកាល
- ការរៀបចំថ្នាលបណ្តុះកូនឈើ
- ដាំដើមឈើតាមផ្ទះ តាមផ្លូវ និងកន្លែងសាធារណៈ

## ជំពូក ៣

## រចនាសម្ព័ន្ធគ្រប់គ្រងសមាគម

ប្រការ ៦:គណៈកម្មាធិការគ្រប់គ្រងសមាគម

ក. សមាសភាគគណៈកម្មាធិការមាន៥រូបគឺប្រធាន អនុប្រធាន លេខាធិការ ហិរញ្ញិក តំណាងកសិករ



ខ. តួនាទីនិងភារៈកិច្ចរបស់គណៈកម្មាធិការគ្រប់គ្រង

១. ប្រធាន :

- មានភារៈកិច្ចជាអ្នកគ្រប់គ្រងទូទៅលើការងាររបស់សមាគម មានសិទ្ធិសំរេចគ្រប់ការងាររបស់សមាគមដោយមានការពិគ្រោះយោបល់ពីគណៈកម្មាធិការទាំង៥រូប ។
- អ្នកដឹកនាំមានផែនការ និងគោលបំណងច្បាស់លាស់ដើម្បីឆ្ពោះទៅរកការរីកចំរើន
- ផ្សព្វផ្សាយនូវចំណេះដឹង និងបទពិសោធន៍ផ្សេងៗដែលខ្លួនទទួលបានពីវគ្គបណ្តុះបណ្តាល ឬកិច្ច
- ដោះស្រាយបញ្ហាផ្សេងៗដែលទាក់ទងទៅនឹងរឿងសមាគម

ពិភាក្សាផ្សេងៗដែលខ្លួនបានចូលរួម ។

២. អនុប្រធាន :

- ជាអ្នកជំនួយការទូទៅក្នុងសមាគម មានសិទ្ធិពិគ្រោះយោបល់ក្នុងការសំរេចការងារផ្សេងៗនៅក្នុងសមាគម
- ធ្វើលិខិតស្នាមផ្សេងៗ
- ផ្សព្វផ្សាយលក្ខន្តិកៈ បទបញ្ញត្តិ និងគោលការណ៍របស់សមាគម
- អប់រំ និងបណ្តុះបណ្តាលលក្ខន្តិកៈ បទបញ្ញត្តិ ច្បាប់ផ្សេងៗ ឬគោលនយោបាយទាំងឡាយទាក់ទងទៅនឹងការជួយលើកកំពស់ក៏រិតជីវភាពប្រជាកសិករ
- ទទួលការងារពេលប្រធានមិននៅ
- បូកសរុប ត្រួតពិនិត្យ និងវាយតំលៃការងាររបស់សមាគម

៣. លេខាធិការ:

- កត់ត្រាធ្វើរបាយការណ៍ និងគ្រប់គ្រងឯកសារផ្សេងៗ
- ធ្វើរបាយការណ៍ និងហេតុការណ៍ដែលកើតមានឡើងនៅក្នុងសមាគម
- សិក្សាធនធាន និងលើកសំណើជូនដល់ប្រធានសមាគម

៤. ហិរញ្ញិក :

- ទទួលបន្ទុករៀបចំធ្វើបញ្ជី និងចំណាយចំណូលថវិការប្រចាំខែ
- រក្សាសុវត្ថិភាពថវិការរបស់សមាគម
- ធ្វើរបាយការណ៍ចំណូលចំណាយជូនដល់អង្គប្រជុំរបស់សមាគម
- ប្រមូលប្រាក់វិភាគទានរាល់ការបង់ប្រាក់របស់សមាជិក និងអ្នកខាងក្រៅ

៥. តំណាងកសិករ :

- ជាអ្នកដែលមានការសំរេចជំនួសកសិករដែលមិនបានចូលរួម
- ទទួលសំរបសំរួលនូវរាល់បញ្ហារបស់កសិករមុននឹងឡើងទៅដល់ប្រធាន

ប្រការ ៧: ការជ្រើសរើសគណកម្មការគ្រប់គ្រង

ដើម្បីអោយក្លាយជាគណកម្មការដឹកនាំបានលុះត្រាតែមានសំលេងគាំទ្រ២/៣នៃសមាជិកពេញសិទ្ធិ ទាំងអស់តាមរយៈការបោះឆ្នោតក្នុងសមាគម

ប្រការ ៨: អាណត្តិគណៈកម្មការ

អាណត្តិគណៈកម្មការគ្រប់គ្រងសមាគមកសិករចំរើនផលពីធម្មជាតិភូមិរំពាក់ពេនមានរយៈពេល៣ ឆ្នាំ។

ប្រការ ៩: ការផ្លាស់ប្តូរគណៈកម្មការគ្រប់គ្រង

- ការផ្លាស់ប្តូរគណៈកម្មការសមាគមទាំងអស់អោយផ្លាស់ប្តូរបានមិនកំណត់ពេលវេលាប្រសិនបើការដឹកនាំមិនរីកចំរើន
- សំណើរដែលអាចអោយប្រធានធ្វើការប្រជុំវិសាមញ្ញបានទាល់តែសមាជិកទាំងអស់មានការលើកសំណើរចំនួន៣០% ទើបប្រធានអាចកោះហៅប្រជុំបាន ។
- ការប្រជុំដើម្បីផ្លាស់ប្តូរគណៈកម្មាធិកាគ្រប់គ្រងអាចប្រព្រឹត្តិទៅបានលុះត្រាមានការលើកសំណើរពីសមាជិកយ៉ាង តិច២/៣ ។
- បន្ទាប់ពីលើកសំណើរពីសមាជិករយៈពេល៧ថ្ងៃគណៈកម្មាធិការគ្រប់គ្រងត្រូវធ្វើការកោះហៅប្រជុំសមាជិកទាំងអស់ដើម្បីធ្វើការពិភាក្សានិងផ្លាស់ប្តូរគម្មាធិការគ្រប់គ្រង
- ការផ្លាស់ប្តូរគណៈកម្មាធិការគ្រប់គ្រងសមាគមថ្មីអាចប្រព្រឹត្តិទៅបានតាមរយៈការបោះឆ្នោត ដោយមានការចូលរួមពីសមាជិកពេញសិទ្ធិទាំងអស់របស់សមាគមដោយមានសំលេង៥០បូក១ទើបអាចផ្លាស់

ប្តូរបាន ។

- គណៈកម្មាធិការថ្មីមកជំនួសគណៈកម្មាធិការចាស់ក្រោយពេលការសំរេច និងផ្ទេរសិទ្ធិយ៉ាងយូរបំផុតរយៈពេល៣ថ្ងៃ ។
- គណៈកម្មាធិការដែលធ្លាក់ពីតំណែងនឹងត្រូវក្លាយជាក្រុមប្រឹក្សាយោបល់ឬក្រុមជំនុំ ។

## ជំពូក ៤

## សមាជិកភាពសមាគម

ប្រការ ១០ :លក្ខខណ្ឌចូលរួមជាសមាជិកចំពោះសមាជិកថ្មី :

- ដាក់ពាក្យសុំជាលាយល័ក្សអក្សរ

- មានការសំរេចចិត្តពីសមាជិកពេញសិទ្ធិ២/៣ហើយប្រធានសមាគមបានប្រកាសក្នុងការប្រជុំប្រចាំខែឬការប្រជុំបំណាច់ឆ្នាំដើម្បីទទួលស្គាល់ជាផ្លូវការ

-បានចូលរួមប្រជុំឬការបណ្តុះបណ្តាលនិងគ្រាំទ្រសកម្មភាពរបស់សមាគម

-សមាជិកដែលចូលថ្មីនោះនិងត្រូវបង់ប្រាក់ស្មើនិងសមាជិកចាស់ទាំងដើមទាំងការ ។

ប្រការ ១១: ការបញ្ឈប់ពីសមាជិកភាព

សមាគមបានព្រមព្រៀងកំណត់បញ្ឈប់សមាជិកភាពតាមគោលការណ៍សំខាន់ៗដែលបានអនុម័តដោយសមាជិកទាំងអស់ ដូចខាងក្រោម :

- សមាជិកដែលបានប្រព្រឹត្តិប្រាស់ចាកពីលក្ខន្តិកៈរបស់សមាគម

- មានការសំរេចពីសមាជិកចំនួន២/៣បាន ប្រកាសក្នុងអង្គប្រជុំប្រចាំខែឬប្រចាំឆ្នាំ សមាជិកដែលចេញមុនពេលកំណត់ ឬអាយុកាល៣ឆ្នាំរបស់សមាគមត្រូវទទួលបានតែប្រាក់ដើម

សំគាល់ :

១.បើមានសមាជិកដែលប្រព្រឹត្តិខុសលក្ខន្តិកៈរបស់សមាគម គឺត្រូវប្រមានលើកទី១បើនៅប្រាស់ចាកពីលក្ខន្តិកៈទៀតត្រូវប្រមានជាលើកទី២ និងលើកទី៣បណ្តេញចេញពីសមាគម ។

២.បើមានសមាជិកចេញមុនកាលកំណត់របស់សមាគម គឺទទួល បានតែប្រាក់ដើម គ្មានសិទ្ធិទទួលប្រាក់ការនិងប្រាក់សង្គ្រោះពីសមាគម ។

## ជំពូក ៥

## ទុនរបស់សមាគម

ប្រភពទុនទៅក្នុងសមាគមកសិករចំរើនផលពីធម្មជាតិភូមិរំពាក់ពេន ឃុំឧត្តមសូរិយា ស្រុកត្រាំកក់ ខេត្តតាកែវបែងចែកជា២ប្រ ភេទគឺប្រាក់ភាគហ៊ុន និងការប្រាក់ ។

ប្រការ ១២ : ប្រាក់ភាគហ៊ុន

សមាជិកពេញសិទ្ធិទាំងអស់ក្នុងសមាគមបានកំណត់ការបង់ភាគហ៊ុនក្នុងប្រាក់ដើមចំនួន ១០០០០រៀលរៀលក្នុងម្នាក់ក្នុងរយៈពេល ៣ឆ្នាំ ។

ប្រការ ១៣: ប្រាក់សង្គ្រោះ

សមាជិកដែលត្រូវបង់ប្រាក់ ៣០០រៀល ក្នុងម្នាក់ក្នុង១ខែដើម្បីជួយដល់សមាជិកនៅពេលមានធុរៈជាបន្ទាន់ ។

នៅពេលមានចុះ:ជាបន្ទាន់សមាជិកមានសិទ្ធិទទួលប្រាក់ទៅតាមស្ថានភាពរបស់ជំងឺ ហើយការផ្តល់ប្រាក់នោះត្រូវសំរេចដោយសមាជិកដែលចូលរួមសន្សំប្រាក់ទាំងអស់ តែក្នុងករណីដែលត្រូវជួយនោះ គឺសមាជិកដែលចូលរួមជាសមាជិកសន្សំប្រាក់សង្គ្រោះតែប៉ុណ្ណោះ អ្នកដែលមិនចូលរួមបង់គ្មានសិទ្ធិទទួលយកឡើយ។ ដំណើរការនៃការប្រើប្រាស់ ប្រាក់សង្គ្រោះនឹងចែងក្នុងច្បាប់ស្តីពីការប្រើប្រាស់ប្រាក់សង្គ្រោះដាច់ដោយឡែក។

ប្រការ ១៤: ប្រាក់របស់សមាជិកភាព ( ទុនទ្រង់)

ដើម្បីអោយដំណើរការប្រព្រឹត្តិទៅបានល្អ និងរលូនសមាគមបានកំណត់បង់ប្រាក់ចំនួន ២០០រៀល/ខែក្នុងរយ:ពេល៣ឆ្នាំ និងប្រសិនបើចង់បង់ប្រចាំឆ្នាំវិញស្មើ ២៤០០រៀល/៣ឆ្នាំ ។ប្រាក់នេះសំរាប់ប្រើប្រាស់ដើម្បីជាប្រយោជន៍ផ្សេងៗក្នុងសមាគម ដូចជាការចំណាយប្រជុំប្រចាំខែសំរាប់ទិញសំភារ: ការធ្វើដំណើរបំរើអោយសមាគមជាដើម។ ប្រាក់មានប្រភពពីការ បង់វិភាគទានរបស់សមាគម និងការឧបត្ថម្ភផ្សេងៗ ( អង្គការ /ស្ថាប័ន សប្បុរសជន ) ។

ប្រការ ១៥ : ប្រាក់សន្សំរបស់សមាជិកសមាគម

ដើម្បីអោយដំណើការទៅបានល្អសមាគមបានសំរេចបង់ប្រាក់ ១០០០រៀល/ខែរយ:ពេល៣ឆ្នាំហើយប្រាក់ទាំងនោះខ្ចីបានតែសមាជិកក្នុងសមាគម តែអ្នកខាងក្រៅអាចខ្ចីបានក្នុងករណីនៅសល់ដើម្បីអោយប្រាក់បំរើផលប្រយោជន៍ដល់សមាគម ។

## ជំពូក ៦

## ការបែងចែកផលប្រយោជន៍

ប្រការ ១៦ : ការប្រើប្រាស់ប្រាក់ភាគហ៊ុន

ប្រាក់ភាគហ៊ុនរបស់សមាគមអាចបែងចែកគ្នាបានលុះត្រាណាតែដល់អណ្តិតសមាគម។ ការបែងចែកនេះប្រព្រឹត្តិនៅចុងឆ្នាំទី៣ហើយបែងចែកស្មើគ្នាទាំងដើមទាំងការដោយគិតតាមចំនួនសមាជិកសរុប ។

ប្រការ ១៧: ប្រាក់ឧបត្ថម្ភក្រៅសមាគម និងបែងចែកផលប្រយោជន៍

សមាជិកទូទៅដែលអនុវត្តន៍នៅកន្លែងគំរូដូចជា សួនបន្លែ កសិដ្ឋានពហុប្រយោជន៍ ស្រូវតាមគោលការណ៍ធម្មជាតិ ( ប វ ស ) ។សមាជិកនោះនឹងមានសិទ្ធិទទួលប្រាក់លើកទឹកចិត្ត ៥០%នៃប្រាក់ឧបត្ថម្ភសរុប ក្នុងពេលទស្សន:កិច្ចមួយលើកៗ

ក. បើទស្សន:កិច្ចសិក្សាក្នុងកសិដ្ឋានឬកន្លែងគំរូផ្សេងៗរបស់កសិដ្ឋាន២ទៅ៣កន្លែងក្នុងនោះនឹងមានការបែងចែកទៅនឹងចំនួនកន្លែង ។

ខ. ប្រាក់ដែលនៅសល់ ៥០%ត្រូវតំកល់ទុកនៅក្នុងសមាគមសំរាប់ដោះស្រាយផ្សេងៗមានការរៀបចំការប្រជុំដូចជាទិញប៊ិច សៀវភៅ ការធ្វើដំណើរ និងវត់ការផ្សេងៗក្នុងសមាគម ។

គ. សមាជិកផ្សេងៗទៀតមិនមានសិទ្ធិទទួលយកឡើយ ។

## ជំពូក ៧

## ការប្រើប្រាស់ប្រាក់សមាគម

ប្រការ ១៨ :ការប្រើប្រាស់ប្រាក់ភាគហ៊ុន

ក.បុគ្គលជាសមាជិកក្នុងសមាគមបានចងក្រងប្រាក់ពីសមាគម សមាគមបានកំណត់យកការប្រាក់ ៣%ក្នុង១ខែ នឹងត្រូវបង់ការប្រាក់ដល់សមាគមយ៉ាងទៀងទាត់រៀងរាល់ខែ ។

ខ.ប្រាក់សមាគមនឹងត្រូវអោយសមាជិកក្រៅសមាគមខ្ចីផងដែរ ក្នុងករណីការប្រាក់សមាគមសល់ច្រើនដោយមានការសំរេចពីសមាជិកទាំងអស់ជាមុនសិនទើបមានសិទ្ធិអ្នកខាងក្រៅខ្ចី ។ សមាគមត្រូវបានកំណត់យកការប្រាក់ ៤. ភាគរយក្នុង១ខែ ហើយការប្រាក់ត្រូវបង់អោយទៀតទាត់រៀងរាល់ខែ ។

គ.កំណត់រយៈពេល ៣ខែ ចំពោះសមាជិកដែលខ្ចីប្រាក់(ក្នុង និងក្រៅសមាគម) ត្រូវយកទាំងដើមទាំងការនៅពេលគំរប់រយៈពេលបីខែ

ឃ. ករណីមានសមាជិកសមាគម និងសមាជិកខាងក្រៅសមាគមមិនបង់ការប្រាក់មកអោយសមាគមជាទៀតទាត់ប្រចាំខែដែលមានចែងក្នុងលក្ខន្តិកៈសមាគមកំណត់បង្វិលការប្រាក់ទៅជាប្រាក់ដើមបន្ថែមទៀតដោយគិតការ ប្រាក់ប្រចាំខែកើនឡើងជាលំដាប់ទៅតាមខែបន្តបន្ទាប់ ។

ឧទាហរណ៍: ប្រសិនបើអ្នកខ្ចីលុយនៅថៃ២៧ខែ១១ឆ្នាំ២០០៣ត្រូវសងការវិញនៅថ្ងៃទី២៧ខែ១២ឆ្នាំ២០០៣ ហើយត្រូវសងទាំងដើមទាំងការនៅថ្ងៃទី២៧ខែ២ឆ្នាំ២០០៤

ង.ករណីប្រសិនលើសរយៈពេលកំណត់គឺយើងអាចពន្យាពេលរហូតដល់៣ខែហើយប្រធានត្រូវមានវិធានការដាស់តឿនរហូត

ច.ក្នុងករណីដែលខ្ចីលុយមានរយៈពេលមិនទាន់គ្រប់រយៈពេល១ខែតែមានលុយសងវិញក៏ត្រូវគិតការប្រាក់ពេញខែដែរគឺ ៣ភាគរយក្នុង១ខែ ។ (ច្បាប់លក្ខខណ្ឌនៃការខ្ចីលុយនៅខាងក្រោយ)

ឆ: បើមានកសិករណាមួយមានចេតនាមិនព្រមបង់ប្រាក់ជូនតាមកំណត់ដែលបានព្រមព្រៀងគ្នាសមាគម មានសិទ្ធិរឹបអូសទ្រព្យសម្បត្តិដែលមានតំលៃស្មើរនឹងប្រាក់ដែលបានខ្ចី ។

ប្រការ ១៩: ការប្រាក់ដែលប្រើប្រាស់សំរាប់ឧបត្ថម្ភផ្សេងៗ

- ប្រើប្រាស់បានតែក្នុងប្រយោជន៍របស់សមាគម
- ជារៀងរាល់ខែដែលបានប្រជុំប្រធានត្រូវតែរៀបរាប់រាល់ការចំណាយ និងចំណូលរបស់សមាគម ប្រាប់ដល់សមាជិក ទាំងអស់ដោយពុំមានការលាក់លៀម ។

## ជំពូក ៨

## សុពលភាពសមាគម

ប្រការ ២០:ព័ត៌មានសមាគម

គ្រប់សមាជិកពេញសិទ្ធិទាំងអស់របស់សមាគមមានការសង្ស័យ ឬឆ្ងល់លើរឿងអ្វីមួយទាក់ទងទៅនឹងរឿងរបស់សមាគម សមាជិកនោះត្រូវមកសួរគណៈកម្មាធិការទាំង៥រូបនៅក្នុងសមាគមដើម្បីអោយដឹងព័ត៌មានច្បាស់លាស់ ។

ប្រការ ២១ :ប្រសិទ្ធិភាពលក្ខន្តិកៈ

លក្ខន្តិកៈនេះត្រូវបានកំណត់ទាំងអស់នៅក្នុងសមាគមបានអនុម័តយល់ព្រមក្នុងពេលបោះឆ្នោតរើស គណៈកម្មការដឹកនាំដែលនឹងធ្វើឡើងនៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៤ ដោយមានការទទួលស្គាល់ពីលោកប្រធានភូមិរំពាក់ពេន លោកមេឃុំឧត្តមសូរិយា លោកឃី គីមថានប្រធានគំរោងកែលំអករីតជីវភាពគ្រួសារកសិករក្រីក្រប្រចាំ ស្រុកត្រាំកក់ និងតំណាងអ្នកសំរប សំរួលមូលដ្ឋាននៃមជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា(សេដាក) ។

បញ្ជាក់បន្ថែមៈ ចំពោះចំណុចដែលមិនមាននៅក្នុងលក្ខន្តិកៈនេះ សមាគមបានចែងនៅក្នុងបន្ថែមទៀត ។

### **បទបញ្ជាផ្ទៃក្នុងសំរាប់សមាគម**

យោងតាមការប្រជុំពិភាក្សាក្នុងក្រុមសមាគមកសិករចំរើនផលពីធម្មជាតិភូមិរំពោក់ពេន ឃុំឧត្តមសូរិយាស្រុកត្រាំកក់ ខេត្តតាកែវ បានសំរេចថានឹងបង្កើតច្បាប់សំរាប់ក្រុមដើម្បីទុកអនុវត្តន៏ច្បាប់នេះមាន :

- ការប្រជុំក្រុមប្រព្រឹត្តិទៅជាទៀងទាត់នៅថ្ងៃទី០១រៀងរាល់ខែ
- ការប្រជុំចាប់ផ្ដើមពីម៉ោង២ដល់ម៉ោង៥ល្ងាច
- សមាជិកក្រុមមកពុំទាន់ពេលនឹងត្រូវផាកពិន័យ
- ការប្រជុំនិយាយតែការងារកសិកម្ម និងប្រាក់សន្សំតែប៉ុណ្ណោះ
- នៅពេលប្រជុំប្រចាំខែសមាជិកត្រូវតែបង់ប្រាក់១000រៀលជាកំណត់
- ឈប់គ្មានច្បាប់ឬគ្មានអ្នកតំណាងមកជំនួសត្រូវផាកជាទឹកប្រាក់៥00រៀល
- ឈប់ត្រូវតែមានច្បាប់ឬមានអ្នកតំណាង
- មិនអនុញ្ញាតិអោយខ្ចីប្រាក់យកទៅប្រើប្រាស់ក្រៅពីការងារកសិកម្ម
- ការខ្ចីប្រាក់ត្រូវដាក់ពាក្យស្នើសុំមុនការប្រជុំ១ថ្ងៃ
- អ្នកខ្ចីប្រាក់ត្រូវបង់ការប្រាក់ជារៀងរាល់ខែ
- សមាជិកក្នុងក្រុមពុំមានសិទ្ធិខ្ចីប្រាក់យកទៅអោយអ្នកខាងក្រៅទេ

- សមាជិកទាំងអស់ត្រូវអនុវត្តផែនការណ៏ក្រុមអោយបាន បើអនុវត្តមិនបាននោះត្រូវពិន័យជាសាច់ប្រាក់១០០០០ រៀល
- រៀងរាល់ការប្រជុំសមាជិកទាំងអស់ត្រូវមានរបាយការណ៏ពីលទ្ធផលការងារកសិកម្មរបស់ខ្លួន
- សមាជិកដែលបានខ្ចីប្រាក់សមាគម ប្រសិនបើមិនសងទាំងដើមទាំងការនោះរហូតដល់ពេល១ខែត្រូវដកហូតសំភារៈដែលមានតំលៃស្មើ
- សមាជិកដែលត្រូវគេតាមអញ្ជើញអោយចូលរួមប្រជុំបើមិនព្រមមកទេ ឬគ្មានអ្នកតំណាងត្រូវផាកពិន័យ៥០០ រៀល។

ធ្វើនៅថ្ងៃទី..25..ខែ..04....ឆ្នាំ ២០០៤

ប្រធានសមាគម

ហត្ថលេខា

បានឃើញ និងទទួលស្គាល់

ធ្វើនៅថ្ងៃទី..27..ខែ..04...ឆ្នាំ ២០០៤

លោក មេភូមិរំពាក់ពេន

ហត្ថលេខា

បានឃើញ និងដឹងឮ

ថ្ងៃទី..25...ខែ...04...ឆ្នាំ ២០០៤

អ្នកសំរបសំរួលតំរោង

ហត្ថលេខា

លោក យី គីមថាន

បានឃើញ និងដឹងឮ

ថ្ងៃទី...26..ខែ...04..ឆ្នាំ ២០០៤

អ្នកសំរបសំរួលនៅតាមមូលដ្ឋាន

ហត្ថលេខា

លោក យឹម ប៊ុនឡុង

ធ្វើនៅថ្ងៃទី..27..ខែ..04..ឆ្នាំ ២០០៤

លោកមេឃុំឧត្ដមសូរិយា

ហត្ថលេខា

## បញ្ជីឈ្មោះសមាជិកសមាគម

| ល.រ | ឈ្មោះ | ភេទ | ភូមិ | មុខងារ | ហត្ថលេខា |
|---|---|---|---|---|---|
| ១ | ទូន កន | ប | រំពាក់ពេន | | |
| ២ | អ៊ុក សុខ | - | - | | |
| ៣ | សុខ ផល្លា | - | - | | |
| ៤ | ហែម សុខុន | ស | - | | |
| ៥ | សៅ សាយ | ប | - | | |
| ៦ | ផូ ផាសិត | - | - | | |
| ៧ | អ៊ុង សេង | ប | - | | |
| ៨ | ញ៉ៀម នី | - | - | | |
| ៩ | ស្វាយ សារុន | - | - | | |
| ១០ | សៅ សុន | - | - | | |
| ១១ | នួន ភា៉ | - | - | | |
| ១២ | ស្រី គីមហុង | - | - | | |
| ១៣ | អន ខន | - | - | | |
| ១៤ | សុខ សារី | ស | - | | |
| ១៥ | ប៊ិត សុខា | ប | - | | |
| ១៦ | ប៉ោង ផៃ | - | - | | |
| ១៧ | គួយ សំ | - | - | | |
| ១៨ | ស៊ឹម មីន | - | - | | |
| ១៩ | ញឹម គួយ | - | - | | |

របាយការណ៍សរុបលទ្ធផលនៃសិក្ខាសាលាស្តីអំពី

# "ការអភិវឌ្ឍន៍មូលដ្ឋាន ១"

ស្រុកត្រាំកក់ ថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០០៣

រៀបចំដោយ សេដាក

Report of workshop on

# "Local Development I"

Tramkok, September 10, 2003

Organized by **CEDAC**


អ្នករៀបចំសិក្ខាសាលា :

**លោក យើ គិមថាន**

**កញ្ញា ម៉ុក មិត្តា**

អ្នកសរសេររបាយការណ៍ :

**លោក លឹម សុវៀត**

## ១. សេចក្តីផ្តើម

មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា ជាអង្គការមិនមែនរដ្ឋាភិបាលខ្មែរ ឯករាជ្យ មិនស្វែងរកកំរៃផលប្រយោជន៍បុគ្គល និងមិនពាក់ព័ន្ធគណបក្សនយោបាយ។ សេដាក បានត្រូវបង្កើតឡើងនៅឆ្នាំ ១៩៩៧ ក្នុងគោលបំណងចូលរួមអភិវឌ្ឍន៍សង្គមកម្ពុជាមួយប្រកបដោយចិរភាព និងសមធម៌ ដែលប្រជាកសិករ និងអ្នកបរិភោគមានជីវិតរស់នៅប្រកបដោយភាពសប្បាយរីករាយ។

សេដាក បានចាប់ដៃគូជាមួយកសិករ និងអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីផ្តួចផ្តើមគំនិតអនុវត្ត និងគាំទ្រដល់ គំរោងឬសកម្មភាពដែលចូលរួមចំណែកដល់អធិបតេយ្យភាពស្បៀង និងការបង្កើននូវគុណភាពជីវិតរបស់ប្រជាកសិករ និងអ្នកបរិភោគដោយជាមួយនោះរក្សា និងបង្កើននូវគុណភាពនៃធនធានធម្មជាតិ និងការសហការ គ្នាក្នុងសង្គម។

ដើម្បីចូលរួមចំណែកក្នុងការសំរេចនូវទស្សនៈវិស័យរបស់ខ្លួន ទើបនៅឆ្នាំ ២០០១ សេដាក បានចាប់ផ្តើមអនុវត្តគំរោងអភិវឌ្ឍន៍សាកល្បងមួយក្នុងភូមិចំនួន ១១ របស់ស្រុកត្រាំកក់។ អាស្រ័យដោយបទពិសោធន៍នៃការ អនុវត្តគំរោងនេះ និងមានការជួយឧបត្ថម្ភថវិការពី ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន ( JICA ) ទើបនៅ ឆ្នាំ ២០០៣ នេះ សេដាក បានធ្វើការពង្រីកភូមិគោលដៅរបស់ខ្លួនរហូតដល់ ៦០ ភូមិ ក្នុងឃុំចំនួន ១៤ នៅក្នុងស្រុកត្រាំកក់។ គំរោងនេះមានការផ្តោតការយកចិត្តទុកដាក់ខ្ពស់ទៅលើការអភិវឌ្ឍន៍ និងផ្សព្វផ្សាយបច្ចេក ទេសកសិកម្មតាមគោលការណ៍ធម្មជាតិ និងព្រមទាំងការបង្កើតបណ្តាញអភិវឌ្ឍន៍មូលដ្ឋានដែលដឹកនាំដោយសមាគមកសិករ។ គំរោងនេះមានរយៈពេល ៣ ឆ្នាំ ដោយចាប់ពីថ្ងៃទី ០១ មករា ២០០៣ ដល់ ៣១ ធ្នូ ២០០៥។

ដើម្បីសំរេចនូវគោលដៅ និងគោលបំណងរបស់គំរោង យើងបានអនុវត្តនូវយុទ្ធសាស្ត្រ និងវិធីសាស្ត្រមួយចំនួនដូចខាងក្រោម:

- បណ្តុះបណ្តាលបច្ចេកទេសកសិកម្មតាមគោលការណ៍ធម្មជាតិដល់កសិករ
- ផ្តល់នូវការគាំទ្រ និងជួយពង្រឹងស្ថាប័នរបស់អង្គការកសិករនៅតាមមូលដ្ឋាន
- ផ្តល់នូវការគាំទ្រផ្នែកទីផ្សារដល់សមាគមកសិករដោយភ្ជាប់ពួកគេជាមួយនឹងបណ្តាញអ្នកប្រើប្រាស់នៅទីក្រុងភ្នំពេញ និងតំបន់ទីប្រជុំជននានា
- កែលំអរនូវប្រព័ន្ធឥណទានដែលមានការប្រាក់ទាប ជាពិសេសតាមរយៈក្រុមសន្សំប្រាក់ និងការផ្តល់ឥណទានពិសេសសំរាប់អភិវឌ្ឍន៍កសិកម្មដោយអង្គការ សេដាក។

ដូចនេះដើម្បីអោយគំរោងមានដំណើរការទៅល្អ និងផ្តល់នូវការគាំទ្រពីអាជ្ញាធរដែនដី និងអ្នកពាក់ព័ន្ធ និងជួយពង្រឹងអំនាចស្ថាប័នរបស់អង្គការកសិករនៅតាមមូលដ្ឋាន ទើបគំរោងរៀបចំអោយមានវេតិការថ្នាក់ឃុំ ឬសិក្ខាសាលានេះឡើងក្នុងគោលបំណង:

ចែករំលែកបទពិសោធន៍គ្នាទៅវិញទៅមករវាងកសិករ និង កសិករ

- បង្កើនការសហការគ្នារវាង សេដាក និងកសិករ
- ទស្សនៈក្នុងការអភិវឌ្ឍន៍មូលដ្ឋាន

**អ្នកចូលរួម**

អ្នកចូលរួមសរុបទាំងអស់ចំនួន នាក់ ស្រី នាក់ ដែលក្នុងនោះមានបុគ្គលិកអង្គការសេដាក ៤នាក់ និងកសិករ នាក់ ( សូមមើលឧបសម្ព័ន្ធទី ១ ) ។

## ២. វិធីសាស្ត្រសិក្ខាសាលា

- ការណែនាំអោយស្គាល់គ្នា និងបង្ហាញពីគោលបំណងនៃសិក្ខាសាលា
- ការលេងល្បែងកំសាន្ត
- ការពិភាក្សាជាក្រុម
- ការឡើងបង្ហាញលទ្ធផលនៃការពិភាក្សា
- វេទិកាសំនួរចំលើយ
- ការបូកសរុប

## ៣. លទ្ធផលនៃសិក្ខាសាលា

### ៣.១. ការបង្ហាញនូវចំណាប់អារម្មណ៍ និងប្រកាសបិទកម្មវិធីសិក្ខាសាលា ដោយលោក តា [illegible] ជំទប់ទីមួយឃុំគុស

- មានភាពរំភើបរីករាយ
- សង្កេតឃើញថាប្រជាកសិករមានជំនឿយ៉ាងខ្លាំងចំពោះសេដាក ( ចង់ចេះ ចង់ឃើញ )
- ថ្លែងអំណរគុណចំពោះសេដាកដែលជួយដល់ប្រជាពលរដ្ឋក្រីក្រ
- សំណូមពរអោយប្រជាកសិករខិតខំក្រេបយកបច្ចេកទេសល្អៗពីសេដាក និងយកទៅផ្សព្វផ្សាយបន្តដល់កសិករដទៃទៀតនៅក្នុងភូមិ

### ៣.២. ការពិភាក្សាជាក្រុម

អ្នកសំរបសំរួលបានបែងចែកក្រុមពិភាក្សាចំនួន ៦ក្រុម សំរាប់ធ្វើការពិភាក្សា ហើយក្នុងសិក្ខាសាលានេះមានការពិភាក្សាចំនួន ២ដង គឺពេលព្រឹកម្តង និងពេលល្ងាចម្តង ។

#### ៣.២.១. ការពិភាក្សាជាក្រុមលើកទី ១

**សំនួរសំរាប់កសិករធ្វើការពិភាក្សា**

១. តើកន្លងមកសេដាកបានជួយគាំទ្រអ្វីខ្លះដល់កសិករ ?

- តើអង្គការសេដាកខុសពីអង្គការដទៃយ៉ាងដូចម្តេច ?

២. តើការសហការជាមួយសេដាកបាននាំមកនូវផលប្រយោជន៍អ្វីខ្លះដល់ :

ក. ខ្លួនឯង

ខ. សំរាប់គ្រួសារ

គ. សំរាប់កសិករក្នុងភូមិ

៣. តើទៅថ្ងៃមុខចង់សហការជាមួយសេដាកដែរឬទេ ?

ក. ការគាំទ្ររបស់សេដាក

ខ. ការចូលរួមចំណែករបស់សហគមន៍

**លទ្ធផលនៃការពិភាក្សាក្រុម ១**

**១/.** កន្លងមកសេដាកបានផ្តល់បច្ចេកទេសផ្សេងៗដូចជា ស្រូវ១ដើម និងចិញ្ចឹមសត្វតាមគោលការណ៍ធម្មជាតិ។

- អង្គការសេដាកខុសពីអង្គការដទៃដូចតទៅ :

| **អង្គការសេដាក** | **អង្គការដទៃ** |
|---|---|
| - ផ្តល់នូវចំណេះដឹង | - បណ្តាក់ទុនអោយប្រជាកសិករដើម្បីយកចំនេញ |
| - ការសន្សំជីធម្មជាតិ | |
| - ការពង្រាបជីស្រែ | |
| - ការរើសពូជ | |
| - ការកាត់បន្ថយជីគីមី | |
| - ការកាត់បន្ថយថវិកាចំនាយក្នុងគ្រួសារ និងបង្កើនសុខភាពកសិករ | |

**២/.** ការសហការជាមួយសេដាកបានផ្តល់នូវផលប្រយោជន៍ដូចជា :

ក. ខ្លួនឯង : ចំណេះដឹង

ខ. គ្រួសារ : មានការរីកចំរើន

គ. កសិករក្នុងភូមិ : ផ្តល់នូវបទពិសោធន៍ដល់កសិករក្នុងភូមិ

**៣/.** ទៅថ្ងៃមុខ ចង់សហការជាមួយសេដាកបន្តទៀត

ក. សូមអោយសេដាកជួយពង្រីកការបណ្តុះបណ្តាលបច្ចេកទេស និងចំនេះដឹងអោយបានទូលំទូលាយ មានទស្សនកិច្ចសិក្សានៅតំបន់ផ្សេងៗ

ខ. យើងទាំងអស់គ្នាជាសហគមន៍ប្តេជ្ញាគាំទ្រសេដាកគ្រប់ពេលវេលា

**លទ្ធផលនៃការពិភាក្សាក្រុម ២**

១/. កន្លងមកសេដាកផ្តល់បច្ចេកទេសសេដ្ឋកិច្ច និងកសិកម្មដូចជា បច្ចេកទេសដំនាំស្រូវ-សៀវភៅព្រឹត្តិបត្តប្រចាំខែ-ដឹកនាំទស្សនកិច្ចនៅមូលដ្ឋានផ្សេងៗ-បើកវគ្គសិក្សាសាលាថ្នាក់ឃុំ និងវគ្គបណ្តុះបណ្តាលបច្ចេកទេសដំនាំស្រូវតាមភូមិ ផ្តល់អំនោយលើកទឹកចិត្តដូចជាអាវយឺត ថ្លៃសាំងម៉ូតូ-ផ្តល់ពូជសណ្តែកសំរាប់ជាវត្ថុធាតុដើមជីកំប៉ុស្ត។

- អង្គការសេដាកខុសពីអង្គការដទៃ គឺអង្គការសេដាកមានទិសដៅ : កាត់បន្ថយភាពក្រីក្រ-ប្រើពូជតិច-ផ្សំជីកំប៉ុស្ត-ស្ទូង១ដើម និងត្រង់ជួរ-កាត់បន្ថយការប្រើជីគីមី និងថ្នាំពុល-កែសំរួលដី-ដាំដើមឈើ។ ឯអង្គការផ្សេងគឺគេបណ្តាក់ទុន។

២/. ការសហការជាមួយសេដាកបានផ្តល់ផលប្រយោជន៍ដូចជា :

ក. ខ្លួនឯង : ចំនេះដឹង បច្ចេកទេស កាត់បន្ថយកំលាំងពលកម្ម ចំនេញពេលវេលា

ខ. សំរាប់គ្រួសារ : ចំណាយពូជតិចបានទិន្នផលខ្ពស់ សល់ថវិកាពីការទិញជីគីមី និងថ្នាំពល

គ. កសិករក្នុងភូមិ : គេឃើញធ្វើបានល្អ គេនឹងសាកល្បងតាម

៣/. ទៅថ្ងៃមុខចង់សហការជាមួយសេដាកបន្តទៀត :

ក. ការគាំទ្ររបស់សេដាក : ចំនេះដឹង និងធនធានមនុស្ស

ខ. សហគមន៍ចូលរួមគាំទ្រ និងចង់បានបច្ចេកទេស

**លទ្ធផលនៃការពិភាក្សាក្រុម ៣**

១/. សេដាកបានជួយគាំទ្រកសិករ និងផ្តល់បច្ចេកទេសចិញ្ចឹមមាន់-ជ្រូកតាមគោលការណ៍ធម្មជាតិ ស្រូវ១ដើម និងរបៀបធ្វើជីកំប៉ុស្ត។

- អង្គការសេដាកខុសពីអង្គការដទៃដូចតទៅ :

| **អង្គការសេដាក** | **អង្គការដទៃ** |
| --- | --- |
| - បង្រៀនបច្ចេកទេសចិញ្ចឹមមាន់-ជ្រូកតាមគោលការណ៍ធម្មជាតិ<br>- បច្ចេកទេសស្រូវ១ដើម : ទុកពូជ បច្ចេកទេសសាបថ្មី | - ផ្តល់សំភារៈ ជីគីមី អណ្តូង ផ្លូវ ស្ពាន<br>- ផ្តល់ឥណទានលុយយកការប្រាក់តិច |

២/. ការសហការជាមួយសេដាកបានផ្តល់ផលប្រយោជន៍ដូចជា :

ក. ខ្លួនឯង : ចំនេះដឹង និងបច្ចេកទេសបង្កបង្កើនផល

ខ. គ្រួសារ : កាត់បន្ថយពូជ ជី បង្កើនទិន្នផលខ្ពស់ អស់ទុនតិច និងបានបច្ចេកទេសជួយដល់គ្រួសារអោយសំបូរសប្បាយ

គ. កសិករក្នុងភូមិ : កើនឡើងឈានទៅកាន់ការរីកចំរើន

៣/. ចង់សហការជាមួយសេដាកបន្តទៀត :

ក. សេដាកជួយផ្តល់បច្ចេកទេសបន្ថែមទៀត

ខ. សហគមន៍រៀនសូត្រចេះដឹងហើយ យើងនឹងយកចំនេះដឹងនេះទៅផ្សព្វផ្សាយដល់ប្រជាជនក្នុងភូមិ

**លទ្ធផលនៃការពិភាក្សាក្រុម ៤**

១. សេដាកបានផ្តល់បច្ចេកទេសកសិកម្ម ចិញ្ចឹមសត្វ និងឯកសារផ្សេងៗ។

- អង្គការសេដាកខុសពីអង្គការដទៃទៀត អង្គការសេដាកបាននាំកសិករទៅមើលការដកពិសោធន៍រវាងកសិករ និងកសិករ ។

២. ការសហការជាមួយសេដាកបានផ្តល់នូវផលប្រយោជន៍ :

ក. ខ្លួនឯង : ចំនេះដឹង បច្ចេកទេសស្រូវ១ដើម-ចិញ្ចឹមមាន់តាមគោលការណ៍ធម្មជាតិ ការជ្រើសរើសពូជ

ខ. គ្រួសារ : ចំរើនផលចំណូលក្នុងគ្រួសារអោយធូរធារជាងមុន

គ. កសិករក្នុងភូមិ : អោយគេឃើញថាល្អ នោះគេនឹងយកទៅធ្វើតាម

៣. ចង់សហការជាមួយសេដាកបន្តទៀត។

ក. សេដាកផ្តល់ផលប្រយោជន៍ដល់កសិករ

ខ. សហគមន៍ចូលរួមប្រជុំអោយបានទៀងទាត់

**លទ្ធផលនៃការពិភាក្សាក្រុម ៥**

១/. សេដាកផ្តល់នូវ : បច្ចេកទេសស្រូវ១ដើម-កាត់បន្ថយការប្រើពូជច្រើន-កាត់បន្ថយការប្រើជីគីមី-ធ្វើអោយដីផុសស្រូវងាយចាក់ឫសដើម្បីលូតលាស់-កាត់បន្ថយកំលាំងពលកម្មមនុស្ស-កាត់បន្ថយការប្រើថ្នាំពុលគីមី-បច្ចេកទេសធ្វើជីកំប៉ុស្ត-ធ្វើអោយប្រសើរនូវកំរិតជីវភាព-ផ្តល់គំនិតក្នុងការត្រាំពូជស្រូវ។

- អង្គការសេដាកខុសពីអង្គការដទៃទៀត អង្គការសេដាកផ្តល់តែបច្ចេកទេសក្នុងការដាំដុះ-មិនផ្តល់ពូជ-ចុះជួយគំនិតរាល់១ខែដល់កសិករ-មិនទាញយកប្រយោជន៍ពីកសិករ ។

២/. ការសហការជាមួយសេដាកបានផ្តល់នូវផលប្រយោជន៍ :

ក. ខ្លួនឯង : រីកចំរើនគំនិតថ្មីប្លែក សាមគ្គីទូលំទូលាយរវាងកសិករ និងកសិករ ស្គាល់មូលដ្ឋាននានា

ខ. គ្រួសារ : ជីវភាពធូរធារជាងមុន មិនប្រើកំលាំងពលកម្មច្រើន( មនុស្ស-សត្វ) កាត់បន្ថយចំនាយ កាត់បន្ថយពេលវេលា មិនប៉ះពាល់សុខភាពគ្រួសារ

គ. កសិករក្នុងភូមិ : ផ្តល់គំនិតថ្មីពីកសិករ១ ទៅកសិករ១ទៀត-ធ្វើជាគំរូដល់កសិករក្នុងភូមិ-ធ្វើអោយកសិករក្នុងភូមិមានការជឿជាក់

៣/. ចង់បន្តការសហការជាមួយសេដាកទៀត :

ក. សេដាកជួយនាំកសិករទៅទស្សនកិច្ចនៅកន្លែងណាដែលគេមានបទពិសោធន៍ល្អមុនយើង-ជួយផ្តល់គំនិតថ្មីទៀតអោយបានញឹកញាប់

ខ. សហគមន៍ចំនាយពេលចូលរួមប្រជុំ និងសិក្ខាសាលាពីសេដាក-ចង់ចូលរួមជាមួយសេដាក និងផ្សព្វផ្សាយដល់កសិករដទៃទៀតក្នុងមូលដ្ឋាន

**លទ្ធផលនៃការពិភាក្សាក្រុម ៦**

១/. សេដាកបានផ្តល់នូវការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម( ស្រូវ ) ។

- អង្គការសេដាកខុសពីអង្គការដទៃដូចតទៅ :

| **អង្គការសេដាក** | **អង្គការដទៃ** |
|---|---|
| - មិនយកកំរៃពីប្រជាជន | - ចងការប្រាក់ |
| - ផ្សព្វផ្សាយស្រូវ-ចិញ្ចឹមសត្វ | - មិនបានផ្សព្វផ្សាយបច្ចេកទេសដល់ប្រជាជន |
| - របៀបធ្វើជីធម្មជាតិ | - គិតតែប្រយោជន៍ផ្ទាល់ខ្លួន |

២/. ការសហការជាមួយសេដាកបានផ្តល់នូវផលប្រយោជន៍ :

ក. ខ្លួនឯង : ទទួលបានចំណេះដឹង

ខ. គ្រួសារ : កាត់បន្ថយការប្រើជីគីមី

គ. កសិករក្នុងភូមិ : ផ្សព្វផ្សាយអោយប្រជាជនក្នុងភូមិបានយល់ដឹង

៣/. ចង់សហការជាមួយសេដាកបន្តទៀត :

ក. ចង់អោយសេដាកផ្តល់បច្ចេកទេសផ្សេងទៀត

ខ. សហគមន៍នៅតែបន្តការសហការទៅមុខទៀត

### ៣.២.២. ការពិភាក្សាជាក្រុមលើកទី ២

**សំនួរសំរាប់កសិករធ្វើការពិភាក្សា**

វិភាគពីស្ថានភាព និងបញ្ហាដែលទាក់ទងទៅនឹងកសិកម្ម និងការអភិវឌ្ឍន៍មូលដ្ឋាន :

១. ផលិតកម្មដំណាំ និងការផ្គត់ផ្គង់ស្បៀង

២. ជីជាតិដី

៣. ប្រាក់ចំណូលគ្រួសារ

៤. ការចំណាយលើជីគីមី-ថ្នាំពុល

៥. ការចំណាកស្រុក

៦. អំពើហឹង្សាក្នុងគ្រួសារ

៧. ដើមឈើ

៨. សត្វព្រៃ និងសត្វមានប្រយោជន៍

៩. ត្រីធម្មជាតិ

១០. ការសហការគ្នាក្នុងភូមិ

**លទ្ធផលនៃការពិភាក្សាជាក្រុម**

វិភាគពីស្ថានភាព និងបញ្ហាដែលទាក់ទងទៅនឹងកសិកម្ម និងការអភិវឌ្ឍន៍មូលដ្ឋាន :

**១/.** ផលិតកម្មដំណាំមានជួបនូវបញ្ហាមួយចំនួនដូចជា ខ្វះប្រភពទឹក និងមធ្យោបាយប្រើប្រាស់ទឹក ទឹកជំនន់ ខ្វះបច្ចេកទេស ពូជមានទិន្នផលទាប ហើយផលិតកម្មដំណាំស្រូវមានជួបបញ្ហាដូចជា ក្រាស៊ី ក្របាម តឿ ងាប់ ដង្កូវស៊ីក្តាមកាត់។ រីឯការផ្គត់ផ្គង់ស្បៀងទៅមានការខ្វះខាតនៅឡើយ ។

**២/.** ដីខ្វះជីជាតិដោយសារ ខ្វះរុក្ខជាតិធ្វើជីកំប៉ុស្ត និងខ្វះបច្ចេកទេសផ្សំជីធម្មជាតិ អស់ព្រៃឈើ ប្រើជីគីមីច្រើនធ្វើអោយខូចគុណភាពដី មិនចេះកែប្រែគុណភាពដី ។

**៣/.** ប្រាក់ចំណូលក្នុងគ្រួសារតិចតួចជាងចំណាយដោយសារ គ្មានទីផ្សារ គ្មានដំណាំរួមផ្សំ ការចំណាយទៅលើការទិញជីគីមី និងថ្នាំពុល ។

**៤/.** ការចំណាយទៅលើជីគីមី និងថ្នាំពុលអស់ប្រាក់ជាច្រើន ( ជីគីមីយ៉ាងតិច ២- ៥បាវ/គ្រួសារ ) ហើយមិនមានគុណភាពទៅនឹងទិន្នផលដែលទទួលបានទៀត ។

**៥/.** ការចំណាកស្រុកមានពី ១០-៣០% ទៅរកមុខរបរផ្សេង បណ្តាលមកពីការផ្គត់ផ្គង់ក្នុងគ្រួសារមិនគ្រប់គ្រាន់ ។

**៦/.** អំពើហឹង្សាក្នុងគ្រួសារមាន ៥% មកពីភាពក្រីក្រ ហូបចុកមិនគ្រប់គ្រាន់ និងខ្វះខាតចំនេះដឹង ។

**៧/.** ដើមឈើបាត់បង់អស់ស្ទើរទាំងស្រុង ដែលបណ្តាលមកពីការកាប់បំផ្លាញ និងការកាប់ប្រើប្រាស់រួចមិនបានដាំដុះឡើងវិញ ធ្វើអោយមានការខ្វះខាតអុសដុត ខ្វះខាតឈើសំរាប់ប្រើប្រាស់ផ្សេងៗ និងកើតមានគ្រោះធម្មជាតិ ។

៨/. សត្វព្រៃបាត់បង់ និងផុតពូជអស់ស្ទើរតែទាំងស្រុង បណ្តាលមកពីអស់ព្រៃឈើខ្វះជំរក និងការប្រមាញ់។ ឯសត្វមានប្រយោជន៍ដូចជា ជន្លេន កង្កែប ហ៊ីង គីង្គក់ និងសត្វស្លាបជាច្រើនត្រូវបានបាត់បង់អស់ ១ចំនួនធំ ដោយសារពួកគេមិនបានយល់ថាសត្វទាំងនេះជាសត្វដែលមានប្រយោជន៍ និងការប្រើប្រាស់ជីគីមី និងថ្នាំពុល។

៩/. ត្រីធម្មជាតិបាត់បង់អស់ជាច្រើនដោយសារ កំនើនប្រជាជនកាន់តែច្រើន ខ្វះប្រភពទឹកធម្មជាតិ ការប្រើជីគីមី និងថ្នាំពុលច្រើន និងការនេសាទដោយប្រើឧបករណ៍ខុសច្បាប់។

១០/. ការសហការគ្នាក្នុងភូមិមិនបានល្អ មិនមានការពិភាក្សាគ្នា និងផ្លាស់ប្តូរចំណេះដឹងគ្នាទៅវិញទៅមក ដោយសារខ្វះការយល់ដឹង ដូច្នេះគួរតែពង្រឹងការសហការគ្នាអោយបានល្អដើម្បីចូលរួមថែរក្សាព្រៃឈើ កាត់បន្ថយការប្រើជីគីមី និងថ្នាំពុល និងទប់ស្កាត់ការនេសាទត្រីខុសច្បាប់។

### ៣.៣. ការប្រមូលសរុបលទ្ធផលនៃការពិភាក្សាជាក្រុម (ដោយលោក ឃី គឹមថាន)

**ការអភិវឌ្ឍន៍សេដ្ឋកិច្ច :**

- យើងត្រូវកាត់បន្ថយរបស់នាំចូលពីខាងក្រៅ (ជីគីមី-ថ្នាំពុល និងឧបករណ៍ប្រើប្រាស់ផ្សេងៗ) ដែលនាំអោយមានលំហូរលុយចេញទៅក្រៅប្រទេស (ក្នុងភូមិ១ដែលមានប្រជាជន១០០គ្រួសារ ត្រូវចំណាយទៅលើជីគីមីអស់ប្រមាណ ១២០លានរៀល/ឆ្នាំ)។

- បង្កើនប្រាក់ចំណូលតាមរយៈការបង្កើតក្រុមកសិករដាំដំណាំសរីរាង្គដែលមិនប្រើជីគីមី និងថ្នាំពុល នោះសេដាកនឹងជួយរកទីផ្សារអោយ ដោយមានតំលៃខ្ពស់ជាងធម្មតា។

**ធនធានធម្មជាតិ :**

- ព្រៃឈើត្រូវបាត់បង់អស់ ដោយសារការកាប់បំផ្លាញ និងមិនដាំដុះឡើងវិញ។

ដូច្នេះយើងត្រូវរួបរួមគ្នាបង្កើតសហគមន៍ដាំដើមឈើឡើងវិញនៅតាមភូមិ តាមវត្តអារាម សាលារៀន និងតាមដងផ្លូវ ហើយ សេដាកនឹងជួយគាំទ្រចំពោះការបង្កើតថ្នាលបណ្តុះកូនឈើតាមវត្ត និងតាមភូមិ និងការចងក្រងសហគមន៍ដាំដើមឈើឡើងវិញនេះ។

- ត្រីធម្មជាតិត្រូវបានបាត់បង់អស់ជាច្រើនដោយសារ ការប្រើឧបករណ៍ខុសច្បាប់ (ឆក់) បណ្តាលអោយមានការខ្វះខាតក្នុងជីវភាព។

ដូច្នេះយើងត្រូវបង្កើតសហគមន៍ការពារត្រីឡើងវិញ គឺយើងអាចសហការគ្នា ដោះដូរបទពិសោធន៍គ្នាទៅវិញទៅមក និងបានពិភាក្សាគ្នាក្នុងការដោះស្រាយបញ្ហាផ្សេងៗ។

### ៣.៤. ចំណាប់អារម្មណ៍របស់សិក្ខាកាម

- ជីវភាពកសិករមានភាពខ្វះខាតច្រើនដោយសារប្រាក់ចំណូលមានតិចតួច ឯប្រាក់ចំណាយច្រើនដូចជាការចំណាយលើការប្រើជីគីមី និងថ្នាំពុលគឺច្រើនមែនទែន ការចំណាយលើឧបករណ៍ប្រើប្រាស់ផ្សេងៗដោយមិនបានប្រើធនធានដែលអាចរកបានក្នុងភូមិ (កន្ទុះគោ ខ្មែរគោ...)

ដូច្នេះប្រជាជនយើងត្រូវចេះយល់ដឹង និងកាត់បន្ថយការប្រើប្រាស់ជីគីមី បែរមកប្រើជីធម្មជាតិវិញ និងធ្វើការដាំដើមឈើដែលជាប្រភពជីធម្មជាតិ នោះវាជាគន្លឹះមួយដើម្បីទប់ស្កាត់នូវបញ្ហាទាំងនេះបាន រីឯអង្គការសេដាកបានព្យាយាមរិះរកវិធីសាស្ត្របែបបុរាណៗដែលប្រើប្រាស់តែធនធានដែលយើងមាន  សំដៅកាត់បន្ថយចំនាយរបស់ប្រជាជន។ ម្យ៉ាងទៀតយើងត្រូវបង្កើនការផ្សព្វផ្សាយអោយបានទូលំទូលាយដល់ប្រជាជន។

- ត្រីធម្មជាតិបាត់បង់ដោយការប្រើឧបករណ៍នេសាទខុសច្បាប់  ហើយការឆក់ត្រីនេះធ្វើអោយគ្រោះថ្នាក់ដល់ប្រជាជនទូទាំងភូមិ ( ការឆក់ត្រីម្តងធ្វើអោយត្រីឈប់កូនរយៈពេល ៦ឆ្នាំ)

ដើម្បីបំបាត់ការនេសាទខុសច្បាប់នេះយើងត្រូវចេះភ្ញាក់រលឹកដោយខ្លួនឯង ចេះសហការគ្នា និងជួយផ្សព្វផ្សាយពីផលលំបាករបស់វា នោះទើបយើងអាច ថែរក្សាធនធានឡើងវិញបាន

- ព្រៃឈើចេះតែកាប់បំផ្លាញ មិនដែលបានដាំឡើងវិញ បណ្តាលអោយបាត់បង់ទាំងសត្វព្រៃជាច្រើនទៀត
- សំណូមពរអោយសិក្ខាកាមដែលបានចូលរួមក្នុងសិក្ខាសាលានេះ  ជួយពាំនាំយកចំនេះដឹងទៅផ្សព្វផ្សាយបន្តដល់ប្រជាជនយើងដទៃទៀតផង

## ឧបសម្ព័ន្ធទី ១ : បញ្ជីវត្តមានអ្នកចូលរួមសិក្ខាសាលាស្តីពី "ការអភិវឌ្ឍន៍មូលដ្ឋាន"

### ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៣

| ល.រ | ឈ្មោះ | ភេទ | ភូមិ | ឃុំ | ស្រុក |
|---|---|---|---|---|---|
| ០១ | អ៊ុន ធា | ប | ឫស្សីស្រុក | ញ៉ៀងញ៉ង | ត្រាំកក់ |
| ០២ | សួន ម៉ៅ | ប | ឫស្សីស្រុក | ញ៉ៀងញ៉ង | ត្រាំកក់ |
| ០៣ | សៅ យ៉ាន់ | ប | តាតែ | ញ៉ៀងញ៉ង | ត្រាំកក់ |
| ០៤ | ង៉ែត ប៉ាល | ប | តាតែ | ញ៉ៀងញ៉ង | ត្រាំកក់ |
| ០៥ | សែម ណាក់ | ប | តាតែ | ញ៉ៀងញ៉ង | ត្រាំកក់ |
| ០៦ | តុប ប៉ែត | ប | តាតែ | ញ៉ៀងញ៉ង | ត្រាំកក់ |
| ០៧ | រត់ រើន | ប | តាតែ | ញ៉ៀងញ៉ង | ត្រាំកក់ |
| ០៨ | មាស គឹង | ប | អូរស្ងើន | ញ៉ៀងញ៉ង | ត្រាំកក់ |
| ០៩ | មឿង ស៊ីថា | ប | អូរស្ងើន | ញ៉ៀងញ៉ង | ត្រាំកក់ |
| ១០ | ឈុប ញ៉ាំង | ប | អូរស្ងើន | ញ៉ៀងញ៉ង | ត្រាំកក់ |
| ១១ | ឯក ភ័ក្រ | ប | អូរស្ងើន | ញ៉ៀងញ៉ង | ត្រាំកក់ |
| ១២ | មៃ ស | ប | កំសី | ញ៉ៀងញ៉ង | ត្រាំកក់ |
| ១៣ | ឡាយ ជួង | ប | កំសី | ញ៉ៀងញ៉ង | ត្រាំកក់ |
| ១៤ | សែម បុត្រ | ប | កំសី | ញ៉ៀងញ៉ង | ត្រាំកក់ |
| ១៥ | ទឹម ឌី | ប | កំសី | ញ៉ៀងញ៉ង | ត្រាំកក់ |
| ១៦ | អ៊ុន សារឿន | ប | កំសី | ញ៉ៀងញ៉ង | ត្រាំកក់ |
| ១៧ | កែវ គឹម | ប | អង្គតាសោម | ញ៉ៀងញ៉ង | ត្រាំកក់ |
| ១៨ | ស នឹម | ស | អង្គតាសោម | ញ៉ៀងញ៉ង | ត្រាំកក់ |
| ១៩ | អិន វ៉ាន់ | ប | អង្គតាសោម | ញ៉ៀងញ៉ង | ត្រាំកក់ |
| ២០ | ញាន មុំ | ស | អង្គតាសោម | ញ៉ៀងញ៉ង | ត្រាំកក់ |
| ២១ | ហង់ ហៀប | ស | ឫស្សីស្រុក | ញ៉ៀងញ៉ង | ត្រាំកក់ |
| ២២ | យ៉ែម នី | ប | ឫស្សីស្រុក | ញ៉ៀងញ៉ង | ត្រាំកក់ |
| ២៣ | អែម ធី | ប | ស្លែងកោង | ញ៉ៀងញ៉ង | ត្រាំកក់ |
| ២៤ | ឈុប គន | ប | ស្លែងកោង | ញ៉ៀងញ៉ង | ត្រាំកក់ |
| ២៥ | គាត់ សុខុម | ប | កំសី | ញ៉ៀងញ៉ង | ត្រាំកក់ |

| | | | | | |
|---|---|---|---|---|---|
| ២៦ | ប៉ុយ តា | ប | ឫស្សីស្រុក | ញ៉ែងញ៉ង | ត្រាំកក់ |
| ២៧ | អ៊ុន អឿន | ប | ឫស្សីស្រុក | ញ៉ែងញ៉ង | ត្រាំកក់ |
| ២៨ | ឈឹម ស៊ន់ | ប | ស្លែងកោង | ញ៉ែងញ៉ង | ត្រាំកក់ |
| ២៩ | ទៀប អ៊ឹម | ប | អូរស្ទើន | ញ៉ែងញ៉ង | ត្រាំកក់ |
| ៣០ | ប៊ិច តុលា | ស | កំសី | ញ៉ែងញ៉ង | ត្រាំកក់ |
| ៣១ | ខឹម ទីន | ប | កំសី | ញ៉ែងញ៉ង | ត្រាំកក់ |
| ៣២ | ចី ទន | ប | ឫស្សីស្រុក | ញ៉ែងញ៉ង | ត្រាំកក់ |
| ៣៣ | ធ ឌុល | ប | ក្រុមប្រឹក្សាឃុំ | ញ៉ែងញ៉ង | ត្រាំកក់ |
| ៣៤ | ប៉ាន់ សារឿន | ប | ជំទប់ទី ២ឃុំ | ស្រែរនោង | ត្រាំកក់ |
| ៣៥ | តា រ៉ | ប | ជំទប់ទី ១ឃុំ | គុស | ត្រាំកក់ |
| ៣៦ | ណែម ហារី | ប | មេឃុំ | គុស | ត្រាំកក់ |
| ៣៧ | អ៊ុន ឆេង | ប | ជំទប់ទី ២ឃុំ | គុស | ត្រាំកក់ |
| ៣៨ | បៃ អ៊ីង | ប | ស្លែងកោង | ញ៉ែងញ៉ង | ត្រាំកក់ |
| ៣៩ | ឈុន ចន្ថា | ស | ត្រពាំងថ្នល់ | ស្រែរនោង | ត្រាំកក់ |
| ៤០ | កោ យេន | ស | ត្រពាំងថ្នល់ | ស្រែរនោង | ត្រាំកក់ |
| ៤១ | ញ៉ាញ់ ញ៉ឹម | ប | ត្រពាំងថ្នល់ | ស្រែរនោង | ត្រាំកក់ |
| ៤២ | ហៀក គ្រិល | ប | ត្រពាំងទន្លាប់ | ស្រែរនោង | ត្រាំកក់ |
| ៤៣ | ឈុង ជីវង | ប | ត្រពាំងទន្លាប់ | ស្រែរនោង | ត្រាំកក់ |
| ៤៤ | ង៉ែត ខេម | ប | ត្រពាំងទន្លាប់ | ស្រែរនោង | ត្រាំកក់ |
| ៤៥ | ម៉ាន់ សុខា | ប | ត្រពាំងទន្លាប់ | ស្រែរនោង | ត្រាំកក់ |
| ៤៦ | អ៊ុង ចេន | ប | ត្រពាំងទន្លាប់ | ស្រែរនោង | ត្រាំកក់ |
| ៤៧ | ជិន សុភី | ប | ទឹកថ្លា | គុស | ត្រាំកក់ |
| ៤៨ | វិន ហៃ | ប | ព្រៃឈ្នួល | គុស | ត្រាំកក់ |
| ៤៩ | ឆែម រិន | ប | ព្រៃឈ្នួល | គុស | ត្រាំកក់ |
| ៥០ | វិន ឈឿន | ប | ទឹកថ្លា | គុស | ត្រាំកក់ |
| ៥១ | នៃ ហ៊ុន | ប | ព្រៃឈ្នួល | គុស | ត្រាំកក់ |
| ៥២ | អួន សារិន | ប | អកពង | គុស | ត្រាំកក់ |
| ៥៣ | ណុប ណាំង | ប | អកពង | គុស | ត្រាំកក់ |

| | | | | | |
|---|---|---|---|---|---|
| ៥៤ | ឆាង សារឿន | ប | អកពង | គុស | ត្រាំកក់ |
| ៥៥ | ឃិន សម្បត្តិ | ប | អកពង | គុស | ត្រាំកក់ |
| ៥៦ | រស់ សំអឿន | ស | គុសថ្មី | គុស | ត្រាំកក់ |
| ៥៧ | គុក សាមួន | ស | គុសថ្មី | គុស | ត្រាំកក់ |
| ៥៨ | ចាប ជិន | ប | ទំនប់ជ្រៃ | គុស | ត្រាំកក់ |
| ៥៩ | ហេុប អឿន | ប | ព្រៃឈ្មួល | គុស | ត្រាំកក់ |
| ៦០ | មុន សុភាព | ស | ក្រាំងស្វាយ | ស្រែរនោង | ត្រាំកក់ |
| ៦១ | ឯម ជឿន | ស | អកពង | គុស | ត្រាំកក់ |
| ៦២ | ហ៊ឹម ហេង | ប | ទំនប់ជ្រៃ | គុស | ត្រាំកក់ |
| ៦៣ | សាំង សារិទ្ធ | ប | ទំនប់ជ្រៃ | គុស | ត្រាំកក់ |
| ៦៤ | ឱក ហេង | ស | ព្រៃឈ្មួល | គុស | ត្រាំកក់ |
| ៦៥ | តេង គា | ស | ក្រាំងស្វាយ | ស្រែរនោង | ត្រាំកក់ |
| ៦៦ | គង់ ផល្លា | ស | ទំនប់ជ្រៃ | គុស | ត្រាំកក់ |
| ៦៧ | ពៅ ម៉ុម | ស | ត្នោតពង | គុស | ត្រាំកក់ |
| ៦៨ | ព្រំ សុផុន | ស | ត្នោតពង | គុស | ត្រាំកក់ |
| ៦៩ | សៅ សួន | ប | ត្នោតពង | គុស | ត្រាំកក់ |
| ៧០ | អ៊ូ ចន្ទន | ប | ត្នោតពង | គុស | ត្រាំកក់ |
| ៧១ | ណុប សំអាត | ស | ទឹកថ្លា | គុស | ត្រាំកក់ |
| ៧២ | ឯម គៀន | ស | អកពង | គុស | ត្រាំកក់ |
| ៧៣ | ញេប ពាង | ស | ទំនប់ជ្រៃ | គុស | ត្រាំកក់ |
| ៧៤ | ភូ រិត | ស | ក្រាំងស្វាយ | ស្រែរនោង | ត្រាំកក់ |
| ៧៥ | យី គឹមថាន | ប | សេដាក | | ត្រាំកក់ |
| ៧៦ | ម៉ុក ចិន្តា | ស | | | |
| ៧៧ | លឹម សួរៀត | ប | | | |
| ៧៨ | សំណាង | ប | | | |

**ឧបសម្ព័ន្ធទី ២ :** **កម្មវិធីសិក្ខាសាលា**

| ពេលវេលា | កម្មវិធី | អ្នកសំរបសំរួល |
|---|---|---|
| **១១ កញ្ញា ២០០៣** | | |
| ៨:០០-៨:៣០ | ការជួបជុំគ្នា និងចុះឈ្មោះសិក្ខាកាម | ក. ម៉ុក ចិន្តា<br>លោក លឹម សូវៀត |
| ៨:៣០-៩:១០ | ការណែនាំ និង បង្ហាញពីគោលបំនងរបស់សិក្ខាសាលា | លោក យី គីមថាន |
| ៩:១០-៩:២៥ | ការលេងល្បែងកំសាន្ត និង ណែនាំអោយស្គាល់គ្នាទៅវិញទៅមក | ក. ម៉ុក ចិន្តា<br>លោក លឹម សូវៀត |
| ៩:២៥-៩:៤០ | ចំណាប់អារម្មណ៍ស្វាគមន៍ និង បើកសិក្ខាសាលា | លោក តា រ៉ំ ជំទប់ទី១ ឃុំគុស |
| ៩:៤០-១០:៥០ | ការបែងចែកក្រុមពិភាក្សា និង ការពិភាក្សាជាក្រុម | លោក យី គីមថាន<br>ក. ម៉ុក ចិន្តា<br>លោក លឹម សូវៀត |
| ១០:៥០-១១:៥៥ | ការឡើងបង្ហាញលទ្ធផលនៃការពិភាក្សា | លោក យី គីមថាន |
| ១១:៥០-១២:០០ | ការបូកសរុបលទ្ធផលនៃការពិភាក្សា | លោក យី គីមថាន |
| ១២:០០-១៣:៤៥ | សំរាកអាហារថ្ងៃត្រង់ | ក. ម៉ុក ចិន្តា<br>លោក លឹម សូវៀត |
| ១៣:៤៥-១៤:០៥ | លេងល្បែងកំសាន្ត | លោក យី គីមថាន |
| ១៤:០៥-១៥:២០ | ការពិភាក្សាជាក្រុម | លោក យី គីមថាន<br>ក. ម៉ុក ចិន្តា<br>លោក លឹម សូវៀត |
| ១៥:២០-១៦:០០ | ការឡើងបង្ហាញលទ្ធផលនៃការពិភាក្សា | លោក យី គីមថាន |
| ១៦:០០-១៦:២៥ | ការបូកសរុបលទ្ធផលនៃការពិភាក្សា | លោក យី គីមថាន |
| ១៦:២៥-១៦:៥៥ | ចំណាប់អារម្មណ៍របស់ក្រុមប្រឹក្សាឃុំ និង សិក្ខាកាម | លោក យី គីមថាន |
| ១៦:៥០-១៧:១០ | ការលេងល្បែងកំសាន្ត | លោក យី គីមថាន |
| ១៧:១០-១៧:២០ | ការវាយតំលៃលទ្ធផល និង ដំណើរការរបស់សិក្ខាសាលា<br>ដោយសិក្ខាកាម និង ចំណាប់អារម្មណ៍បិទសិក្ខាសាលា | លោក យី គីមថាន |

# ច្បាប់និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុម សាលារៀនសហគមន៍កសិករនៅភូមិ

**កំសី ឃុំញ៉ែងញ៉ង ស្រុកត្រាំកក់ ខេត្តតាកែវ រៀបចំនៅ ថ្ងៃទី២៣ ខែ១១ ឆ្នាំ២០០៣**

**១. សេចក្តីផ្តើម :**

មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា ( សេដាក ) បានអនុវត្តន៍គំរោងអភិវឌ្ឍន៍កសិកម្មមួយនៅក្នុងស្រុកត្រាំកក់ ដែលមានឈ្មោះថា គំរោងកែលំអរជីវភាពគ្រួសារកសិករ ។ គោលបំណងសំខាន់របស់គំរោងគឺបង្កើនជីវភាពគ្រួសារកសិករ តាមរយៈការពង្រឹងសម្ថភាពលើបច្ចេកទេសកសិកម្មតាមគោលការណ៍ធម្មជាតិ និងការគ្រប់គ្រងកសិដ្ឋានចំរុះ ។ ដើម្បីសំរេចបាននូវគោលបំណងនេះគំរោងបានអនុវត្តន៍នូវដំនើរការផ្សព្វផ្សាយពីកសិករទៅកសិករ តាមរយៈវិធីសាស្ត្រមួយចំនួន ជាពិសេសការជួបជុំកសិករជាទៀងទាត់ និងជារៀងរាល់ខែ។ ការជួបជុំគ្នានេះកន្លងមកវាបានផ្តល់គុណសម្បត្តិ និងគុណវិបត្តិផងដែរ ដូចជា :

**គុណសម្បត្តិ :**

- បានយល់ដឹងច្រើនពីបច្ចេកទេសកសិកម្ម
- បានទទួលឯកសាថ្មីៗ
- បានទទួលពតិមានច្រើនល្អៗ
- បានទៅមើលកន្លែងពិសោធន៍ដោយផ្ទាល់ភ្នែកដែលកសិករបានធ្វើ

**គុណវិបត្តិ :**

- កសិករមកជួបជុំមិនទៀងទាត់
- មិនគោរពពេលវេលា
- មិនសូវយកចិត្តទុកដាក់ក្នុងការជួបជុំ និងពិភាក្សា

ដើម្បីធ្វើការជួបជុំនោះកាន់តែមានប្រសិទ្ធិភាពទើបនៅថ្ងៃទី ២៦ /១១/២០០៣ កសិករនៅភូមិស្វែងកោងស្រុកបាន ឯកភាពគ្នាបង្កើតនូវសាលារៀនសហគមកសិករក្នុងគោលបំណងដូចខាងក្រោម :

- ចូលរៀនជាទៀងទាត់រាល់ខែ
- ចេះជួយគ្នាក្នុងក្រុម
- បានជួបជុំគ្នាដើម្បីដោះដូរនៅបទពិសោធន៍
- យល់ដឹងពីការសន្សំប្រាក់
- ទទួលនូវបទពិសោធន៍ថ្មី

២. មានថវិកាសំរាប់យកទៅវិនិយោគផ្សេងៗសមាជិកភាព:

**អ្នកដែលអាចជាសមាជិកភាពរបស់ក្រុមបានទាល់តែ**

- មានការសហការជាមួយសេដាក

- អនុវត្តន៍នូវបច្ចេកទេស ដែលសេដាកបានផ្សព្វផ្សាយ
- ចូលរៀនទៀងទាត់អោយបានរាល់ខែ
- មនុស្សក្នុងភូមិ
- ត្រូវបង់លុយអោយក្រុមទៀងទាត់

**អ្នកដែលសំរេចចិត្តសំរាប់ការចូលជាក្រុមសហគមន៍កសិករគឺកសិករផ្ទាល់ ។**

៣. រចនាសម្ព័ន្ធរបស់ក្រុមៈ




គណៈកម្មការគ្រប់គ្រងក្រុម

*១. ប្រធានៈ* មានតួនាទីជាអ្នក

- ជាអ្នកគ្រប់គ្រងទូទៅលើការងារក្នុងក្រុម និងមានសិទ្ធសំរេចគ្រប់ការងារ ដែលសមស្របនឹងលក្ខន្តិកៈរបស់ក្រុមដោយមានការពិគ្រោះយោបល់ពីសមាជិកគណៈកម្មការទាំងអស់
- ដឹកនាំធ្វើផែនការក្រុម
- ដោះស្រាយបញ្ហាផ្សេង១ក្នុងក្រុម
- ធ្វើការអនុវត្ត និងផ្សព្វផ្សាយនូវកម្មវិធីផ្សេង១ដល់សមាជិក

***២. អនុប្រធានៈ***

- ជាជំនួយការទូទៅក្នុងក្រុមមានសិទ្ធិពិគ្រោះយោបល់ក្នុងការសំរេចការងារផ្សេង១
- ធ្វើលិខិតស្នាមផ្សេង១
- ផ្សព្វផ្សាយលក្ខន្តិកៈ បទបញ្ជាតិ និងគោលការណ៍របស់ក្រុម
- ទទួលការងារពេលប្រធានមិននៅ
- ជ្រើសរើស និងកំនត់ចំនួនសមាជិកសំរាប់ការចូលរួមវគ្គបណ្តុះបណ្តាលផ្សេង១
- កោះអញ្ជើញសមាជិកអោយចូលរួមការប្រជុំ និងចាត់ចែងការងារប្រជុំរបស់ក្រុម

***៣. ហិរញ្ញិកៈ***

- កត់ត្រាធ្វើរបាយការណ៍ និងគ្រប់គ្រងឯកសារផ្សេង១
- ធ្វើរបាយការណ៍ និងរាយការណ៍ពីហេតុការណ៍ដែលកើតមាននៅក្នុងក្រុម

- ទុកដាក់ឯកសារផ្សេងៗរបស់ក្រុម
- ទទួលបន្ទុករៀបចំបញ្ជី និងការចំណាយចំណូលរបស់ក្រុម
- រក្សាសុវត្ថិភាពថវិការបស់ក្រុម
- ធ្វើរបាយការណ៍ចំណាយចំណូលជូនដល់អង្គប្រជុំក្រុម

៤. ធុនរបស់ក្រុម :

- ការសន្សំរបស់សមាជិក ១០០០រៀល/ខែ
- ការឧបត្ថម្ភពីសេដាក១២០០០រៀល/ខែ
- ការប្រាក់ដែលសមាជិកខ្ចី ៣%ដែល ១០០០០រៀល= ៣០០រៀល
- ការប្រាក់ពីអ្នកខាងក្រៅដែលបានខ្ចី ៤%ដែល១០០០០រៀល=៤០០រៀល
- លុយដាក់ពិន័យ

. មកប្រជុំដេកលក់ ១០០រៀល

. អវត្តមានឥតច្បាប់ ៣០០រៀល

. ជជែកគ្នាពេលប្រជុំ ១០០រៀល

. មកយឺតពេល ១០០រៀល

៥. លក្ខន្តិកៈរបស់ក្រុមៈ

៥.១. លក្ខខណ្ឌទូទៅរបស់សមាជិកក្រុម :

- សមាជិកត្រូវចូលរៀនអោយទៀងទាត់
- អវត្តមានត្រូវមានច្បាប់ ( ដោយប្រាប់ដំណឹងអោយក្រុមបានដឹង)
- ចូលរួមសាកល្បងនូវបច្ចេកទេសថ្មី
- មិនត្រូវនិយាយអ្វីដែលដឹងមិនច្បាស់ចេញពីក្រុមទៅប្រាប់អ្នកខាងក្រៅ
- បើមានរឿងមិនល្អពីអ្នកខាងក្រៅត្រូវមកសួរក្រុមជាមុនទើបវាយតំលៃជាក្រោយ
- ត្រូវគោរពមិត្តរួមរបស់ក្រុម

៥.២. លក្ខខណ្ឌការសន្សំប្រាក់និងការខ្ចីប្រាក់ :

- សមាជិកក្រុមត្រូវបង់លុយអោយទៀងទាត់បើចង់សន្សំប្រាក់
- ប្រាក់ដែលក្រុមសន្សំត្រូវសមាជិកក្រុមខ្ចីមុនបើករណីចាំបាច់
- មិនត្រូវអោយអ្នកក្រៅក្រុមខ្ចីមុនសមាជិកក្រុមទេ
- ពេលខ្ចីត្រូវសងទៅតាមការកំណត់របស់ក្រុម
- សមាជិកអាចមានសិទ្ធិខ្ចីលើកទី២បានលុះត្រាតែបង់លុយដែលបានខ្ចីលើកទី១អោយរួចជាមុនសិន
- ភាគហ៊ុនរបស់ក្រុមត្រូវទទួលផលបានស្មើគ្នា
- សមាជិកក្រុមដែលខ្ចីលុយមិនសងត្រូវមានពីរករណី :

. ត្រូវមានការដាស់តឿន ១ទៅ ២ដង

. រិបអូសរបស់ដែលមានតំលៃស្មើ

. បញ្ឈប់ចេញពីក្រុម ឬ ទុកអោយក្រុមជាអ្នកសំរេច

. ទុកពេលវេលាអោយរយៈពេល៧-១០ថ្ងៃ

- អ្នកខាងក្រៅខ្ចីត្រូវមានការប្រាក់ខុសពីសមាជិកក្រុម

- សមាជិកស្លាប់ត្រូវមានការបែងចែកផលប្រយោជន៍ស្មើគ្នា

- សមាជិកផ្លាស់ទីលំនៅត្រូវមានការបែងចែកផលប្រយោជន៍ស្មើគ្នាបើសិនជាមាន លក្ខខណ្ឌត្រឹមត្រូវ

- បើខ្ចីលើសពី៥០០០០រៀលឡើងទៅត្រូវដឹងឮទាំងប្តី និងប្រពន្ធ

**៥.៣. លក្ខខណ្ឌរបស់អ្នកដែលចង់ចូលរួមជាមួយក្រុម :**

- ប្រសិនបើមានអ្នកខាងក្រៅចាប់អារម្មណ៍ទៅលើការសន្សំប្រាក់ហើយចង់ចូលរួមគឺត្រូវមានលក្ខខណ្ឌដូចជា:
    - សុំការអនុញ្ញាតិពីប្រធាន និងសមាជិករបស់ក្រុមតាមរយៈសម្លេងលើសពី ២/៣ត្រូវអោយអ្នកនោះចូលរួម
    - ភាគហ៊ុនដែលសន្សំត្រូវទទួលបានទៅតាមពេលវេលាដែលបានចូលរួម
    - បើសិនជាករណីចង់អោយមានភាគហ៊ុនស្មើគេត្រូវមានការបង់អោយគ្រប់ទៅតាមភាគហ៊ុនអ្នកមុន
    - ត្រូវគោរពច្បាប់ដែលក្រុមបានរៀបចំ
- ប្រសិនបើមានអ្នកខាងក្រៅចាប់អារម្មណ៍ចង់ខ្ចីលុយ :
    - ការខ្ចីប្រាក់ត្រូវទទួលសំលេងអោយលើស ២/៣ សំលេងលើសពាក់កណ្តាល
    - បើមានករណីសមាជិកណាម្នាក់ហ៊ានអោយលុយខ្ចីដោយមិនមានសមាជិកក្រុមដឹងឮ អ្នកនោះត្រូវទទួលខុសត្រូវដោយខ្លួនឯង
    - ត្រូវមានវត្ថុដែលមានតំលៃស្មើ
    - ទឹកប្រាក់ខ្ចីខ្ពស់បំផុត ៦០០០០រៀល
    - ដឹងឮទាំងប្តី និងប្រពន្ធ
    - ការប្រាក់ ៣ភាគរយក្នុងមួយខែ

## ៦. ការទទួលផលប្រយោជន៍របស់សមាជិកក្រុម :

- មានសិទ្ធិខ្ចីប្រាក់ពីក្រុមមុនគេ
- សុំឈប់ដោយមានដំណឹងច្បាស់លាស់គឺទទួលផលប្រយោជន៍ស្មើគ្នា
- អ្នកចូលរួមស្លាប់ត្រូវបែងចែកផលប្រយោជន៍ស្មើគ្នា
- អ្នកចូលរួមផ្លាស់ទីលំនៅត្រូវបែងចែកផលប្រយោជន៍ស្មើគ្នា
- ពេលមានបញ្ហាក្រុមជាអ្នកសំរេច

## ៧. ការបញ្ឈប់សមាជិកភាព :

- ការបញ្ឈប់សមាជិកភាពត្រូវមានមូលហេតុសមស្របហេតុអ្វី?

ឧទាហរណ៍: មិនគោរពបទបញ្ជាផ្ទៃក្នុង

- ➢ មិនបង់លុយ
- ➢ មិនមកប្រជុំទៀងទាត់ ..........។ល។

- អ្នកត្រូវគេបញ្ឈប់ត្រូវមានមូលហេតុសមស្រប

**៨. បទបញ្ជាផ្ទៃក្នុង**

- ហាមផឹកស្រានៅពេលប្រជុំ បើពេលប្រជុំស្រវឹងត្រូវផាកពិន័យចំនួន១០០រៀល
- ចេះជួយគ្នាក្នុងក្រុម
- មកប្រជុំដេកលក់ ១០០រៀល
- អវត្តមានឥតច្បាប់ ៣០០រៀល
- ជជែកគ្នាពេលប្រជុំ ១០០រៀល
- មកយឺតពេល ១០០រៀល
- គោរពមិត្តរួមរបស់ក្រុម

ធ្វើនៅថ្ងៃទី ...........ខែ...........ឆ្នាំ២០០៣

**ប្រធាន សាលារៀនសហគមកសិករ**

## ៩. បញ្ជីឈ្មោះអ្នកចូលរួម

| ល.រ | ឈ្មោះ | ភេទ | មុខងារ | ផ្សេងៗ |
|---|---|---|---|---|
| ១ | អ៊ុន សារឿន | ប | អនុប្រធាន | |
| ២ | មៃ សរ | ប | ប្រធាន | |
| ៣ | ឡាយ ជួង | ប | | |
| ៤ | សុខ សំអាត | ប | | |
| ៥ | សុខ ឈាន | ប | | |
| ៦ | រីម សួង | ប | | |
| ៧ | ជា សារីម | ស | | |
| ៨ | អ៊ុន ណើ | ស | | |
| ៩ | គន់ ចាន់ | ស | | |
| ១០ | ពេជ្រ ណាក៉ា | ស | | |
| ១១ | ចាប សារី | ស | | |
| ១២ | ជង់ វ៉ាន់ | ប | | |
| ១៣ | ជង់ ងយ | ប | | |
| ១៤ | មិន សំបូរ | ស | | |
| ១៥ | រស់ សិន | ស | | |
| ១៦ | ទីម ឌី | ប | បេឡា | |
| ១៧ | អែម អាន | ប | | |
| ១៨ | គាត់ សុខុម | ប | | |
| ១៩ | ទេព សារ៉ុន | ស | | |
| ២០ | ចាន់ សុខ | ប | | |
| ២១ | ម៉ាក់ ភាព | ប | | |
| ២២ | សែម បុត | ប | | |